# របាយការណ៍

# ស្តីពី

# វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤

# នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

អគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ខែធ្នូ ឆ្នាំ២០១៤

# មាតិកា

I. ខ្លឹមសារសង្ខេប ........................................ 1

II. សេចក្តីផ្តើម ........................................ 2

III. លទ្ធផលសម្រេចបាន........................................ 3

IV. បញ្ហាប្រឈម........................................ 28

V. អនុសាសន៍........................................ 28

VI. សេចក្តីសន្និដ្ឋាន ........................................ 29

## ឧបសម្ព័ន្ធ ក: របាយការណ៍វឌ្ឍនភាព ត្រីមាសទី៣ ឆ្នាំ២០១៤

## I. ខ្លឹមសារសង្ខេប

……………………………………………………………………………………………………………………………………………
……………………………………………………………………………………………………………………………………………
……………………………………………………………………………………………………………………………………………។

## II. សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅឆ្នាំ២០០៤ ដោយមានក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអ្នកដឹកនាំនិងសម្របសម្រួល ក្នុងទិសដៅកែលម្អប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ជាជំហានៗឆ្ពោះទៅរកស្តង់ដារអន្តរជាតិ នៅឆ្នាំ២០២៥ ដោយធ្វើការផ្លាស់ប្តូរជាបណ្តើរៗ ពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅរកប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ។ ទោះយ៉ាងណាក៏ដោយ គោលដៅប្រកបដោយមហិច្ឆតានេះ មិនអាចសម្រេចបានក្នុងរយៈពេលខ្លី និង គ្មានទស្សនៈវិស័យវែងឆ្ងាយនោះទេ។ ក្នុងន័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាកម្មវិធីរយៈពេលវែងនិងគ្រប់ជ្រុងជ្រោយ ដែលការអនុវត្តកម្មវិធីត្រូវបានបែងចែកជាដំណាក់កាលៗ ដោយមានរយៈពេល និង គោលដៅច្បាស់លាស់ តាមដំណាក់កាលនីមួយៗ ដូចតទៅ÷

- ដំណាក់កាលទី១ (២០០៤-២០០៨) ÷ ភាពជឿទុកចិត្តបាននៃថវិកា
- ដំណាក់កាលទី២ (២០០៩-២០១៥) ÷ គណនេយ្យភាពហិរញ្ញវត្ថុ
- ដំណាក់កាលទី៣ (២០១៦-២០២០) ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ
- ដំណាក់កាលទី៤ (២០២១-២០២៥) ÷ គណនេយ្យភាពចំពោះសមិទ្ធកម្ម។

ដំណាក់កាលទី១ នៃភាពជឿទុកចិត្តបាននៃថវិកា បានសម្រេចដោយជោគជ័យ ក្នុងឆ្នាំ២០០៨ ដោយបានប្រែក្លាយពីភាពរ៉ាំរ៉ៃនៃឱនភាពសាច់ប្រាក់ មកជាមានអតិរេកសាច់ប្រាក់ តាមរយៈការបង្កើនការប្រមូលចំណូល និងវិចារណកម្មចំណាយ។ ថ្វីត្បិតតែ ដំណាក់កាលទី១ ទទួលបានជោគជ័យតាមការរំពឹងទុក ក៏ប៉ុន្តែ កំណែទម្រង់ហិរញ្ញវត្ថុសាធារណៈត្រូវបន្តដំណើរវែងឆ្ងាយទៀត តាមដំណាក់កាលបន្តបន្ទាប់របស់កម្មវិធី។ ក្នុងន័យនេះ បន្ទាប់ពីភាពជឿទុកចិត្តបាននៃថវិកាត្រូវបានរក្សាជាសារវន្តនោះ ការពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ ជាគោលដៅចម្បងនៃដំណាក់កាលទី២ ដែលត្រូវបានអនុវត្តពេញលេញ នៅក្នុងឆ្នាំ២០០៩ តាមរយៈការរៀបចំនិងការអនុវត្តផែនការសកម្មភាព របស់ ក្រសួង ស្ថាប័ន ក៏ដូចជា អគ្គនាយកដ្ឋាននីមួយៗ ចំណុះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ក្នុងគោលដៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ផែនការសកម្មភាពដំណាក់កាលទី២ ផ្តោតជាពិសេសលើការបង្កើនភាពច្បាស់លាស់ សុក្រឹតភាព និងភាពទាន់ពេលវេលានៃប្រព័ន្ធកត់ត្រា និងរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ដែលជាមូលដ្ឋានដ៏សំខាន់សម្រាប់ការវាយតម្លៃនិងវិភាគ ក្នុងគោលដៅបង្កើនប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងតម្លាភាព។ ដំណាក់កាលទី២ គឺជាដំណាក់កាលដ៏សំខាន់បំផុត ក្នុងចំណោមដំណាក់កាលទាំង៤ នៃកម្មវិធីកែទម្រង់ ហើយក៏អាចចាត់ទុកថា ជោគជ័យនៃដំណាក់កាលទី២ គឺជាកត្តាដែលកំណត់ជោគជ័យនៃកម្មវិធីកែទម្រង់ទាំងមូល។ បច្ចុប្បន្ន កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កំពុងស្ថិតនៅក្នុងដំណាក់កាលអន្តរកាល ដែលត្រូវបានអនុវត្ត តាមរយៈផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី (Consolidated Action Plan 2 New) ដើម្បីសម្រេចបញ្ចប់ដំណាក់កាលទី២ គឺ **ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** និងសម្រាប់ ការត្រៀមលក្ខណៈឈានទៅអនុវត្តដំណាក់កាលទី៣ គឺ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ នៅឆ្នាំ២០១៦។**

ផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី (CAP 2 new) នេះ ត្រូវបានគ្រោងសម្រាប់ការអនុវត្តក្នុងរយៈពេល ១ឆ្នាំ និង ៦ខែ មានន័យថាសម្រាប់ឆមាសទី២ ឆ្នាំ២០១៤ និង សម្រាប់ឆ្នាំ២០១៥ទាំងមូល។ ដូចនេះ របាយការណ៍ស្តីពីវឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤ នេះ គឺជារបាយការណ៍ត្រីមាសទី១ ក្នុងក្របខណ្ឌនៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី (CAP 2 new) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ របាយការណ៍នេះ មានភាពខុសគ្នាពីរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ (CAP 2) លើវិធីសាស្រ្តនៃការរាយការណ៍វឌ្ឍនភាពរបស់អគ្គនាយកដ្ឋាននីមួយៗ និងវិធីសាស្រ្តនៃការវាយតម្លៃវឌ្ឍនភាពរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.)។ ចំពោះរបាយការណ៍វឌ្ឍនភាពរបស់អគ្គនាយកដ្ឋាននីមួយៗ ត្រូវរៀបចំតាមទម្រង់របាយការណ៍ថ្មីដែល អ.គ.ហ. បានរៀបចំនិងដាក់ឱ្យអនុវត្ត។ ចំណែកឯ វិធីសាស្រ្តនៃការវាយតម្លៃវឌ្ឍនភាពដោយ អ.គ.ហ. ផ្អែកលើមូលដ្ឋាន ២ គឺ÷

១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត

២. លទ្ធផលសម្រេចបាន ធៀបនឹងសូចនាករគោលដៅ។

របាយការណ៍ស្តីពីវឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤ នៃការអនុវត្តផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នេះ នឹងរៀបរាប់ពីលទ្ធផលសម្រេចបានដោយលម្អិតទៅតាមផ្អែកនីមួយៗ រហូតដល់កម្រិតគោលបំណង និងចង្កោមសកម្មភាព ធៀបនឹងសូចនាករ ព្រមទាំងលើកឡើងពីបញ្ហាប្រឈមនិងអនុសាសន៍/ការងារត្រូវធ្វើបន្តផងដែរ។

## III. លទ្ធផលសម្រេចបាន

## ផ្អែកទី១: ភាពជឿទុកចិត្តបាននៃថវិកា

ផ្អែកទី១ ភាពជឿទុកចិត្តបាននៃថវិកា ក្នុង CAP 2 NEW មានគោលបំណងចំនួន ៤ (១១. ការពង្រឹងការគ្រប់គ្រងចំណូល និងការអនុវត្តផែនការប្រមូលចំណូល, ១២. ការពង្រឹងការគ្រប់គ្រងបំណុល, ១៣. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី និង ១៤. ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ) និងចង្កោមសកម្មភាពចំនួន ១៤ រីឯ ក្នុង CAP 2 មានគោលបំណងចំនួន ៤ តែចង្កោមសកម្មភាពត្រឹម ១៩។ ក្នុងចំណោមគោលបំណងទាំង៤ រវាង CAP 2 និង CAP 2 NEW មានភាពខុសគ្នាត្រង់÷

- **គោលបំណង ១១ ÷** នៅក្នុង CAP 2 គោលបំណងនេះ ផ្តោតលើការបន្តកែលម្អរដ្ឋបាលនិងគោលនយោបាយចំណូល។ នៅក្នុង CAP 2 New ការយកចិត្តទុកដាក់ផ្តោតទៅលើការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូលវិញ។ នៅក្នុង CAP 2 ចង្កោមសកម្មភាពនីមួយៗ ត្រូវមានសកម្មភាពគាំទ្រស្មើរពីគ្រប់អង្គភាពពាក់ព័ន្ធការប្រមូលចំណូល បានសេចក្តីថា គ្មានចង្កោមសកម្មភាពណាមួយ ដែលមានតែមួយអង្គភាពអនុវត្តនោះឡើយ។ ដោយឡែក នៅក្នុង CAP 2 New ចង្កោមសកម្មភាពនីមួយៗ ត្រូវទទួលខុសត្រូវដោយអគ្គនាយក-

ដ្ឋានតែមួយគត់ ក៏ប៉ុន្តែ អគ្គនាយកដ្ឋាននីមួយៗ ត្រូវផ្តល់កិច្ចសហការគ្នាទៅវិញទៅមក ដើម្បីពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល។

- **គោលបំណង ១៤ ÷** ក្នុង CAP 2 New ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ ផ្តោតតាំងពីការធានាចំណាយរហូតដល់ការទូទាត់ មិនត្រឹមតែក្នុងនីតិវិធីចំណាយលទ្ធកម្មសាធារណៈ តែថែមទាំងសម្រាប់ចំណាយក្រៅពីលទ្ធកម្មសាធារណៈផងដែរ ក្នុងគោលដៅធានានីតិវិធីខ្លី ដំណើរការលឿន និងមានប្រសិទ្ធភាព។

ជារួម ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៧៧% ដែលក្នុងនោះ គោលបំណង ១១ សម្រេចបាន ៧៦%, គោលបំណង ១២ សម្រេចបាន ៨០%, គោលបំណង ១៣ សម្រេចបាន ៨៧% និង គោលបំណង ១៤ សម្រេចបាន ៦៤%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានទាបជាង ៥០% គឺ ចង្កោមសកម្មភាព ១១.៣ និង ១២.១។ ទន្ទឹមនេះ បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករគន្លឹះទាំង ៦ និង សូចនាករនៃគោលបំណងទាំង៤ ដើម្បីពង្រឹងនិងគាំទ្រដល់ការសម្រេចបានភាពជឿទុកចិត្តបាននៃថវិកា ជារួម គឺសម្រេចបានតាមគោលដៅនៃសូចនាករដែលបានកំណត់។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៦ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គឺមានសូចនាករ ២ អាចធៀបនឹងគោលដៅសូចនាករ បានតាមរយៈលទ្ធផលសម្រេចបាន ដូចខាងក្រោម÷

១. ចំណូលក្នុងស្រុកអនុវត្តបាន ៧៤,៨% កើនឡើង៦,៣% លើសត្រីមាសទី៣ ឆ្នាំ២០១៣។ ចំណូលក្នុងស្រុកអនុវត្តសរុប ក្នុងឆ្នាំ២០១៣ សម្រេចបាន ៩៩,៦% ដូចនេះ លទ្ធផលសម្រេចបានក្នុងត្រីមាសទី៣នេះ អាចឱ្យសន្និដ្ឋានបានថា ចំណូលក្នុងស្រុកសរុបសម្រាប់ឆ្នាំ ២០១៤ អាចសម្រេចបានក្នុងរង្វង់ +/-៥%នៃច្បាប់។

២. បំណុលសាច់ប្រាក់កកស្ទះ គឺសូន្យ ដែលគោលដៅកំណត់ គឺមិនឱ្យលើសពី ២%នៃចំណាយសរុប។

ដោយឡែកសូចនាករ ៣ទៀត មិនសម្រេចបានតាមគោលដៅ គឺ÷

១. ភាពរលូននៃការអនុវត្តចំណាយក្នុងឆ្នាំ ដែលឆ្លុះបញ្ចាំងអំពីលទ្ធភាពដែលអាណាប័កអាចអនុវត្តចំណាយបានតាមកម្មវិធី។ ចំណាយដែលអនុវត្តបាន គឺ ១៣,៤% សម្រាប់ត្រីមាសទី១ ធៀបនឹងគោលដៅ ១៥%, ៣៣,៣% សម្រាប់ត្រីមាសទី២ ធៀបនឹងគោលដៅ ៤៥% និង៥៦,២% សម្រាប់ត្រីមាសទី៣ ធៀបនឹងគោលដៅ៦៧%។

២. កំណើនចំណូលប្រចាំឆ្នាំ២០១៤ អាចសម្រេចបានលើស ០,៥% នៃ ផ.ស.ស ប្រចាំឆ្នាំ ដោយសារចំណូលក្នុងស្រុក ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ មានកំណើនខ្ពស់ជាងត្រីមាសទី៣ ឆ្នាំ២០១៣ និងម្យ៉ាងទៀត លទ្ធផលសម្រេចបានក្នុងឆ្នាំ២០១៣ មាន ១៣%នៃផសស ។

៣. ការអនុវត្តចំណាយតាមប្រភេទ: ការអនុវត្តនៅត្រីមាសទី៣ ឆ្នាំ២០១៤ ទាបជាងការអនុវត្តនៅត្រីមាសទី៣ ឆ្នាំ ២០១៣ ប្រមាណ ១៥,៦% សម្រាប់បៀវត្ស; ២,៥%សម្រាប់ទំនិញនិងសេវា និង ០,៣% សម្រាប់ចំណាយមូលធន។

ចំណែកឯ សូចនាករមួយទៀត ពុំបានកំណត់គោលដៅច្បាស់លាស់សម្រាប់ជាមូលដ្ឋានក្នុងការវាស់វែងនោះ គឺការពង្រឹងការអនុវត្តគណនីទោលរតនាគារជាតិ។

ដូច្នេះ ជារួម អាចសន្និដ្ឋានបានថាភាពជឿទុកចិត្តបាននៃថវិកា នៅតែរក្សាបានជាសារវន្ត សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នេះ តែមិនទាន់បានបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននោះទេ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល, ពង្រឹងការគ្រប់គ្រងបំណុល, ពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី និងផ្តោតជាពិសេសលើការពង្រឹងនិងកែលម្អការអនុវត្តថវិកានិងការអនុវត្តផែនការចំណាយ។

## ១. លទ្ធផលលើសូចនាករសមិទ្ធកម្មគន្លឹះ

សូចនាករសមិទ្ធកម្មគន្លឹះលើភាពជឿទុកចិត្តបាននៃថវិកា បានសម្រេចជាលទ្ធផល ដូចតទៅ÷

- **សូចនាករទី១** គឺការប្រមូលចំណូលក្នុងស្រុក ដែលនៅត្រីមាសទី៣ ឆ្នាំ២០១៤ អនុវត្តបាន ៧៤,៨% កើនលើសត្រីមាសទី៣ ឆ្នាំ២០១៣ ប្រមាណ **៦,៣%**។ ចំណូលក្នុងស្រុកប្រចាំត្រីមាសទី៣ ឆ្នាំ២០១៤ មានការកើនឡើងធៀបនឹងត្រីមាសទី៣ឆ្នាំ២០១៣ ដោយសារ÷
  - ការកើនឡើងនៃចំណូលពន្ធគយប្រមាណ ៤២%។ ក្នុងនោះ ពន្ធលើការនាំចូលផលិតផលប្រេងកាត មានការកើនឡើង៣៨%; ពន្ធលើការនាំចូលទំនិញសម្រាប់ថែទាំផ្លូវថ្នល់កើនឡើង២៣%; អាករពិសេសលើទំនិញនាំចូលកើនឡើង៦៣% និងអាករលើតម្លៃបន្ថែមលើការនាំចូលកើនឡើង៣១%។
  - ការកើនឡើងនៃចំណូលពន្ធពន្ធដារប្រមាណ៣៤%។ ក្នុងនោះ ពន្ធលើប្រាក់ចំណេញកើនឡើង ៤៨%; ពន្ធលើប្រាក់បៀវត្ស កើនឡើង ៤៤%; ពន្ធលើផលទុនដីធ្លី ផ្ទះសម្បែង កើនឡើង ២៦% និងអាករលើតម្លៃបន្ថែមកើនឡើង២២%។
  - ការកើនឡើងនៃអាករលើការស៊ីណូប្រមាណ ៣១%។
  - ការកើនឡើងនៃចំណូលមិនមែនសារពើពន្ធកើនឡើងប្រមាណ ៥១%។ ក្នុងនោះ ការជួលសហគ្រាសនិងអចលនវត្ថុកើនឡើង ១៨%; ប្រាក់ចំណេញពីសហគ្រាសសាធារណៈ កើនឡើង ៧២%; ផលទុនពីអាកាសចរណ៍ស៊ីវិលកើនឡើង៣៣% និងអាករស្ថានទូតកើនឡើង១០%។
- **សូចនាករទី២** ដែលគោលដៅបានកំណត់ពីបំណុលកកស្ទះមិនឱ្យលើសពី ២% នៃចំណាយសរុប។ ការអនុវត្តជាក់ស្តែងនៅក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ បំណុលកកស្ទះត្រូវបានលុបបំបាត់ពោលគឺសាច់ប្រាក់ត្រូវបានធានាសម្រាប់ការចំណាយទាំងស្រុង។ បំណុលកកស្ទះ គួរត្រូវបានធ្វើការតាមដានត្រួតពិនិត្យជាបន្តទៀត បើទោះបីស្ថានភាពសាច់ប្រាក់ត្រូវបានធានាសម្រាប់ការចំណាយទាំងស្រុងយ៉ាងណាក៏ដោយ ព្រោះការកំណត់តាមដាននេះគឺជាមធ្យោបាយក្នុងការវាស់វែងលើភាពជឿទុកចិត្តបាននៃថវិកាទាំងក្នុងស្ថានភាពវិជ្ជមាន និងទាំងក្នុងស្ថានភាពអវិជ្ជមាន។
- **សូចនាករទី៣** ដែលគោលដៅបានកំណត់ការអនុវត្តចំណាយនៅត្រីមាសទី៣ នៃឆ្នាំនីមួយៗ មិនត្រូវតិចជាង ៦៧%។ ការអនុវត្តជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ ការអនុវត្តចំណាយសម្រេចបានត្រឹមតែ ៥៦,២% ទាបជាងគោលដៅប្រមាណ ១០,៨% និងទាបជាងការអនុវត្តចំណាយប្រចាំត្រីមាសទី៣ ឆ្នាំ២០១៣ ប្រមាណ

១២,៦%។ ការអនុវត្តទាបជាងគោលដៅនេះ ដោយសារតែការកែលម្អការអនុវត្តនីតិវិធីចំណាយ ដើម្បីទទួលបានប្រសិទ្ធភាពប្រសើរជាងមុន។ ការអនុវត្តចំណាយថវិកាបានទាបជាងផែនការនេះ គឺបណ្តាលមកពីការរឹតបន្តឹងការផ្តល់គោលការណ៍ធានាចំណាយនិងការធ្វើលទ្ធកម្មសាធារណៈ ដើម្បីពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តចំណាយ។ អាស្រ័យដោយមូលហេតុនេះ ទើបធ្វើឱ្យមានភាពយឺតយ៉ាវដល់ការអនុវត្តចំណាយថវិកា។ ក្រសួង ស្ថាប័នមួយចំនួន ដែលបានអនុវត្តយឺតយ៉ាវមានដូចតទៅ÷ ១. ក្រសួងរៀបចំដែន នគរូបនីយកម្មនិងសំណង់ ២. រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ៣. ក្រសួងអភិវឌ្ឍន៍ជនបទ និង៤. ក្រសួងធនធានទឹក ជាដើម។

- **សូចនាករទី៤** កំណត់ពីចំណាយតាមប្រភេទ ដែលរួមមាន បៀវត្ស ទំនិញនិងសេវា និងចំណាយមូលធន។ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ចំណាយសម្រាប់បៀវត្សអនុវត្តបាន ៧៤,៣%; ទំនិញនិងសេវា អនុវត្តបាន ៤៣,៧% និងចំណាយមូលធន អនុវត្តបាន ៤៨,៥%។ ការអនុវត្តនៅត្រីមាសទី៣ ឆ្នាំ២០១៤ ទាបជាងការអនុវត្តនៅត្រីមាស ទី៣ ឆ្នាំ២០១៣ ប្រមាណ ១៥,៦% សម្រាប់បៀវត្ស; ២,៥% សម្រាប់ទំនិញនិងសេវា និង ០,៣% សម្រាប់ចំណាយមូលធន។ ការអនុវត្តចំណាយថវិកាបានទាបជាងផែនការនេះ គឺបណ្តាលមកពីការរឹតបន្តឹងការផ្តល់គោលការណ៍ធានាចំណាយនិងការធ្វើលទ្ធកម្មសាធារណៈ ព្រមទាំងការកែទម្រង់មួយចំនួនដូចជាកែទម្រង់ប្រព័ន្ធបើកប្រាក់បៀវត្សតាមប្រព័ន្ធធនាគារនិងទាន់ពេលវេលា ជាដើម។ អាស្រ័យដោយមានការពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តចំណាយនេះ ទើបធ្វើឱ្យមានភាពយឺតយ៉ាវដល់ការអនុវត្តចំណាយថវិកា។

- ☐ **សូចនាករទី៥** ដែលកំណត់ពីភាគរយនៃចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ រួមចំណែកទៅក្នុង ផ.ស.ស. ត្រូវមានកំណើន ០,៥%។ ការអនុវត្តនៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ ចំណូលពន្ធ អនុវត្តបាន ៨១,៥% និងចំណូលមិនមែនសារពើពន្ធ ៦៣,៦% កើនលើសការអនុវត្តក្នុងត្រីមាសទី៣ ឆ្នាំ២០១៣ ចំនួន ១០ % សម្រាប់ចំណូលពន្ធដារ និង ៥,៥% សម្រាប់ចំណូលមិនមែនសារពើពន្ធ។ កំណើនចំណូលនេះបណ្តាលមកពី÷
  - ✓ ការកើនឡើងនៃចំណូលពន្ធគយប្រមាណ៣៦%។ ក្នុងនោះ ពន្ធលើការនាំចូលផលិតផលប្រេងកាតមានការកើនឡើង ១១%; ពន្ធលើការនាំចូលទំនិញសម្រាប់ថៃទាំផ្លូវថ្នល់កើនឡើង ៩%; ពន្ធលើការនាំចេញមានការកើនឡើង ៥៩%; អាករពិសេសលើទំនិញនាំចូលកើនឡើង៤០% និងអាករលើតម្លៃបន្ថែមលើការនាំចូលកើនឡើង៣៥%។
  - ✓ ការកើនឡើងនៃចំណូលពន្ធពន្ធដារប្រមាណ ២១%។ ក្នុងនោះ ពន្ធលើប្រាក់ចំណេញកើនឡើង២៧%; ពន្ធលើប្រាក់បៀវត្សកើនឡើង៣១%; ពន្ធលើផលទុនដីធ្លី ផ្ទះសម្បែង កើនឡើង៣៩%; អាករពិសេសលើទំនិញក្នុងស្រុកកើនឡើង១១% និងអាករលើតម្លៃបន្ថែមកើនឡើង១៤%។
  - ✓ ការកើនឡើងនៃចំណូលមិនមែនសារពើពន្ធកើនឡើងប្រមាណ៣១%។ ក្នុងនោះ សម្បទានព្រៃឈើកើនឡើង ២២%; ប្រាក់ចំណេញពីសហគ្រាសសាធារណៈ កើនឡើង ១០១%; ផលទុនពីអាកាសចរណ៍ស៊ីវិលកើនឡើង ២១%; ការត្រួតពិនិត្យគុណភាពផលិតផល កើនឡើង៥៨% និងអាករស្ថានទូតកើនឡើង៨%។

- **សូចនាករទី៦** គឺការពង្រឹងគណនីទោលរតនាគារ។ គិតចាប់តាំងពីឆ្នាំ២០០៨ មក គណនីទោលរតនាគារត្រូវបានពង្រឹងជាបណ្តើរៗ។ គណនីដែលក្រសួង ស្ថាប័ននានាបានបើកត្រូវបានបិទ និងដាកមកប្រើប្រាស់ គណនីទោល

រតនាគារ សម្រាប់រាល់ប្រតិបត្តិការចំណូលនិងចំណាយ។ គណនីតាមធនាគារចំនួន១.៧៣៥គណនី ត្រូវបានបិទក្នុងប៉ុន្មានឆ្នាំកន្លងទៅ ហើយរហូតមកដល់ពេលនេះ មិនមានការបិទគណនីទៀតទេ ដោយសារមិនមានការបើកគណនីថ្មីដោយគ្មានការអនុញ្ញាតពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុឡើយ។ ដោយឡែក អគ្គនាយកដ្ឋានរតនាគារជាតិនឹងបន្តតាមដានទៀត ជាពិសេសគណនីគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលអស់សកម្មភាពជាដើម។

តារាងខាងក្រោមនេះបង្ហាញជូនជាសង្ខេបនូវលទ្ធផលដោយផ្អែកលើសូចនាករ÷

| **សូចនាករ** | **គោលដៅ** | **វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៣** | **វឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤** |
|---|---|---|---|
| **១. លទ្ធផលចំណូលក្នុងស្រុកសរុប ជាបណ្តើរៗកាន់តែខិតទៅរកគោលដៅដែលបានអនុម័ត នៅក្នុងច្បាប់ហិរញ្ញវត្ថុ** | ចំណូលក្នុងស្រុកសរុបសម្រេចបាន +/-៥% ធៀបនឹងគោលដៅដែលបានអនុម័តក្នុងច្បាប់ | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី១: ២១,៣%<br>☐ត្រីមាសទី២: ៤៨,១%<br>☐ត្រីមាសទី៣: ៦៨,៥% | ចំណូលក្នុងស្រុកសម្រេចបាន÷<br>☐ត្រីមាសទី១: ២២,%<br>☐ត្រីមាសទី២: ៥០,៥%<br>☐ត្រីមាសទី៣: ៧៤,៨% |
| **២. គ្មានការបង្កើតឡើងនូវបំណុលកកស្ទះថ្មី** | បំណុលកកស្ទះត្រូវកម្រិតមិនឱ្យលើសពី ២% នៃចំណាយសរុប | មិនមានបំណុលកកស្ទះ | មិនមានបំណុលកកស្ទះ |
| **៣. អាណាប័កជាបណ្តើរៗអាចបញ្ជាចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់** | ស្ថានភាពចំណាយមិនត្រូវតិចជាង:<br>☐ ត្រីមាសទី១: ១៥%<br>☐ ត្រីមាសទី២: ៤៥%<br>☐ ត្រីមាសទី៣: ៦៧%<br>☐ ត្រីមាសទី៤: ៩៦% | ចំណាយថវិកាជាតិសម្រេចបានក្នុង÷<br>☐ ត្រីមាសទី១: ១៩ %<br>☐ ត្រីមាសទី២: ៣៧,៣%<br>☐ ត្រីមាសទី៣: ៦០,៨% | ចំណាយថវិកាជាតិសម្រេចបានក្នុង÷<br>☐ ត្រីមាសទី១: ១៣,៤%<br>☐ ត្រីមាសទី២: ៣៣,៣%<br>☐ ត្រីមាសទី៣: ៥៦,២% |
| | ភាគរយនៃការទូទាត់ជូនអ្នកផ្គត់ផ្គង់និងបុគ្គលិកតាមប្រព័ន្ធធនាគារមិនត្រូវតិចជាង ៨០%នៃចំណាយសរុប | ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ត្រីមាសទី១: ៩៣ %<br>☐ត្រីមាសទី២: ៩២.៥%<br>☐ត្រីមាសទី៣: ៩២,៣%<br>▪ ក្រសួងចំនួន៣៩ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ (មានតែថ្នាក់ដឹកនាំនៅថ្នាក់រដ្ឋបាលកណ្តាលប៉ុណ្ណោះ | ការទូទាត់តាមប្រព័ន្ធធនាគារសម្រេចបាន÷<br>☐ ត្រីមាសទី១: ១០០%<br>☐ ត្រីមាសទី២: ១០០%<br>☐ ត្រីមាសទី៣: ១០០%<br>▪ ក្រសួងចំនួន ៣៩ បានបើកបៀវត្សតាមប្រព័ន្ធធនាគារ (មន្ត្រីរាជការទូទៅលើកលែង តែរដ្ឋសភា) |
| | ភាគរយនៃការបង់ចំណូលតាមរយៈប្រព័ន្ធធនាគារមិនត្រូវតិចជាង៦០%នៃចំណាយសរុប | ត្រីមាសទី១÷<br>☐ចំណូលពន្ធគយ: ៩១,៥%<br>☐ចំណូលពន្ធដារ: ៩៩,១%<br>ត្រីមាសទី២÷<br>☐ចំណូលពន្ធគយ: ៩៣%<br>☐ចំណូលពន្ធដារ: ៩៣,៨%<br>ត្រីមាសទី៣÷<br>☐ចំណូលពន្ធគយ: ៩១%<br>☐ចំណូលពន្ធដារ: ៨៧,១% | ត្រីមាសទី១÷<br>☐ ចំណូលពន្ធគយ: ៨៩,៧%<br>☐ ចំណូលពន្ធដារ: ១០០%<br>ត្រីមាសទី២÷<br>☐ ចំណូលពន្ធគយ: ៩១%<br>☐ ចំណូលពន្ធដារ: ៩៧,៥%<br>ត្រីមាសទី៣÷<br>☐ ចំណូលពន្ធគយ: ៩៣%<br>☐ ចំណូលពន្ធដារ: ៩២,៣% |

| | | | |
|---|---|---|---|
| **៤. ចំណាយតាមប្រភេទ (សម្រាប់បុគ្គលិក) កាន់តែខិតទៅរកថវិកាដែលបានអនុម័ត** | លទ្ធផលចំណាយធៀបនឹងថវិកាអនុម័តមិនត្រូវតិចជាង÷<br>☐ បៀវត្ស: ៩៨%<br>☐ ទំនិញ/សេវា: ៩៥%<br>☐ មូលធន: ៨៥% | ចំណាយថវិកាជាតិសម្រេចបាន÷<br>ត្រីមាសទី១÷<br>☐ បៀវត្ស: ១៦,៦%<br>☐ ទំនិញ/សេវា: ១០,០១%<br>☐ មូលធន: ១១,៤%<br>ត្រីមាសទី២÷<br>☐ បៀវត្ស: ៥៤,០%<br>☐ ទំនិញ/សេវា: ២៦,២%<br>☐ មូលធន: ២៩,០%<br>ត្រីមាសទី៣÷<br>☐ បៀវត្ស: ៨៩,៩%<br>☐ ទំនិញ/សេវា: ៤៦,២%<br>☐ មូលធន: ៤៨,៨% | ចំណាយថវិកាជាតិសម្រេចបាន:<br>ត្រីមាសទី១:<br>☐ បៀវត្ស: ២២,៩%<br>☐ ទំនិញ/សេវា: ១២,១%<br>☐ មូលធន: ១១,២%<br>ត្រីមាសទី២÷<br>☐ បៀវត្ស: ៤៨,៤%<br>☐ ទំនិញ/សេវា: ២២,៦%<br>☐ មូលធន: ៤១,២%<br>ត្រីមាសទី៣÷<br>☐ បៀវត្ស: ៧៤,៣%<br>☐ ទំនិញ/សេវា: ៤៣,៧%<br>☐ មូលធន: ៤៨,៥% |
| **៥. ទិន្នផលចំណូលលើមូលដ្ឋានពន្ធកាន់តែប្រសើរជាងមុនតាមរយៈការកែលម្អប្រសិទ្ធភាពនៃការប្រមូលនិងផែនការប្រើប្រាស់ប្រភពចំណូលមិនមែនសារពើពន្ធ** | ការរួមចំណែកទៅក្នុង ផសស នៃ ចំណូលសរុបមានការកែលម្អដោយបង្កើនប្រមាណ 0.៥% ក្នុងមួយឆ្នាំ | ✓ **ត្រីមាសទី១÷**<br>▪ ចំណូលពន្ធ÷ ២៧%<br>▪ ចំណូលមិនមែនសារពើពន្ធ: ២៥,៩%<br>✓ **ត្រីមាសទី២÷**<br>▪ ចំណូលពន្ធ: ៤៩,១%<br>- ពន្ធផ្ទាល់: ៥៩,៩%<br>- ពន្ធប្រយោល: ៤៨,៥%<br>▪ ចំណូលមិនមែនសារពើពន្ធ: ៤២,៤%<br>✓ **ត្រីមាសទី៣÷**<br>▪ ចំណូលពន្ធ: ៧១,៥%<br>- ពន្ធផ្ទាល់: ៧៨,៣%<br>- ពន្ធប្រយោល: ៧៣,៤%<br>▪ ចំណូលមិនមែនសារពើពន្ធ÷ ៥៨,១% | ✓ **ត្រីមាសទី១÷**<br>▪ ចំណូលពន្ធ÷ ២៤,២%<br>- ពន្ធផ្ទាល់: ២២,៥%<br>- ពន្ធប្រយោល: ២២,៩%<br>▪ ចំណូលមិនមែនសារពើពន្ធ: ១៦,១%<br>✓ **ត្រីមាសទី២÷**<br>▪ ចំណូលពន្ធ: ៥៤,២%<br>- ពន្ធផ្ទាល់: ៦៤,៣%<br>- ពន្ធប្រយោល: ៤៧,៤%<br>▪ ចំណូលមិនមែនសារពើពន្ធ: ៤៣,២%<br>✓ **ត្រីមាសទី៣÷**<br>▪ ចំណូលពន្ធ: ៨១,៥%<br>- ពន្ធផ្ទាល់: ៨៨,១%<br>- ពន្ធប្រយោល: ៧៥,២%<br>▪ ចំណូលមិនមែនសារពើពន្ធ÷ ៦៣,៦% |
| **៦. រាល់ផ្នែកសំខាន់ៗនៃចំណូលនិងចំណាយសាធារណៈត្រូវបានដាក់បញ្ចូលក្នុងថវិកានិងគណនីរបស់ រដ្ឋាភិបាល** | មិនមានផ្នែកសំខាន់ៗដែលត្រូវបានដកចេញ | គណនីទោលរតនាគារជាតិត្រូវបានបន្តពង្រឹង | គណនីទោលរតនាគារជាតិត្រូវបានបន្តពង្រឹង |

## ២. លទ្ធផលនៃសកម្មភាពគន្លឹះសម្រាប់បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា

ក្រៅពីសូចនាករសមិទ្ធកម្មគន្លឹះទាំង ៦ ខាងលើ សកម្មភាពគន្លឹះមួយចំនួនទៀតត្រូវបានអនុវត្ត ដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកា សំដៅគាំទ្រ **ការធ្វើឱ្យប្រសើរឡើងនូវគណនេយ្យភាពហិរញ្ញវត្ថុ** ដែលជាគោលបំណងយុទ្ធសាស្ត្រនៃដំណាក់កាលទី២។

សកម្មភាពទាំងនេះ ត្រូវបានអនុវត្តក្នុងគោលបំណង ចំនួន ៤ និង ចង្កោមសកម្មភាព ចំនួន ១៤ ដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកា ដែលជាផ្នែកមួយដ៏សំខាន់ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២ ថ្មី។

ការអនុវត្តសកម្មភាពដើម្បីពង្រឹងភាពជឿទុកចិត្តបាននៃថវិកា ទាំងនោះ សម្រេចបានលទ្ធផលដូចតទៅ÷

### ២.១. ការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល

នៅក្នុង CAP 2 គោលបំណង ១១ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា ផ្តោតលើការបន្តកែលម្អរដ្ឋបាល និងគោលនយោបាយចំណូល ដែលគោលបំណងនេះ ត្រូវបានកែសម្រួលមកជា ការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូលវិញ នៅក្នុង CAP 2 New។ រីឯក្នុងកម្រិតចង្កោមសកម្មភាព មានការតម្រឹមចំនួនចង្កោមសកម្មភាពពី ៦ មកត្រឹម ៤ តែប៉ុណ្ណោះ ដែលចង្កោមសកម្មភាពនីមួយៗ ក្នុង CAP 2 New នេះ ត្រូវទទួលខុសត្រូវអនុវត្តដោយអង្គភាពពាក់ព័ន្ធចំណូលនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អគ្គនាយកដ្ឋានដែលទទួលបន្ទុកប្រមូលចំណូល (គយ ពន្ធដារ និងចំណូលមិនមែនសារពើពន្ធ) ត្រូវរៀបចំសកម្មភាពដើម្បីពង្រឹងសមត្ថភាពព្យាករណ៍ សមត្ថភាពគ្រប់គ្រង និងប្រសិទ្ធភាពនៃការប្រមូលចំណូល។ ដោយឡែក អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ ត្រូវដាក់ផែនការក្នុងការពង្រឹងសមត្ថភាពនៃការរៀបចំ សុក្រឹតភាពនៃការព្យាករណ៍ និងប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌនិងគោលនយោបាយចំណូល (Top-Down Approach) ដើម្បីអាចឱ្យអង្គភាពទទួលបន្ទុកប្រមូលចំណូល មានមូលដ្ឋានក្នុងការរៀបចំនិងការអនុវត្ត ផែនការប្រមូលចំណូលប្រចាំឆ្នាំរបស់ខ្លួន (Bottom-Up Approach)។

ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៧៦.៣៤%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានតិចជាង ៥០% នៃគោលដៅគឺចង្កោមសកម្មភាព ១១.៣។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាព នៃគោលបំណង ១១ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា មានសូចនាករ២ សម្រេចតាមគោលដៅ គឺ÷

១. បញ្ហាប្រឈមពាក់ព័ន្ធនឹងទិន្នន័យ និងព័ត៌មានដែលទាក់ទងនឹងមូលដ្ឋានគិតពន្ធ ដើម្បីកែលម្អម៉ូដែលព្យាករណ៍ចំណូលត្រូវបានកំណត់ និង សេចក្តីព្រាងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ត្រូវបានរៀបចំ

២. ការពង្រឹងការគ្រប់គ្រងតាមរយៈការបង្កើតបញ្ជរជាតិតែមួយ (Cambodian National Single Window), ការពង្រីកប្រស្វ័យប្រវត្តកម្មអាស៊ីគូដារ (ASACUDA)

ដោយឡែក សូចនាករ ២ ទៀត មិនសម្រេចបានតាមគោលដៅ គឺ÷

១. ការសិក្សាម៉ូដែលព្យាករណ៍ចំណូលពន្ធដារ និង ការរៀបចំនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យពន្ធដារ

២. ការរៀបចំនិងកែសម្រួលលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធវិស័យទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ។

ដូចនេះ ជារួម តាមរយៈសកម្មភាពនិងលទ្ធផលដែលសម្រេចបាន ការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល នៅតែរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ តែនៅមិនទាន់អាចបង្កើនបានទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយ ដោយសារតែមានសកម្មភាពមួយចំនួនដែលអនុវត្តក្នុងចង្កោមសកម្មភាព ១១.៣ មានភាពយឺតយ៉ាវ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តកែលម្អនិងពង្រឹងសមត្ថភាពនៃការរៀបចំ សុក្រឹតភាពនៃការព្យាករណ៍និងប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌនិងគោលនយោបាយចំណូល ការពង្រឹងសមត្ថភាពព្យាករណ៍ សមត្ថភាពគ្រប់គ្រង និងប្រសិទ្ធភាពនៃការប្រមូលចំណូលគយនិងរដ្ឋាករ ចំណូលពន្ធដារ និងចំណូលមិនមែនសារពើពន្ធ ដើម្បីឆ្ពោះទៅធានាការពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូលប្រកបដោយ ប្រសិទ្ធភាព។

## ២.២. ការពង្រឹងការគ្រប់គ្រងបំណុល

ការពង្រឹងការគ្រប់គ្រងបំណុល ដែលជាគោលបំណងទី២ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មិនមានបម្រែបម្រួលពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណងទី២នេះ មានចង្កោមសកម្មភាពចំនួន ៣ ដោយផ្តោតទៅលើការពង្រឹងការគ្រប់គ្រងបំណុល តាមរយៈចង្កោមសកម្មភាព ១២.១. ពិនិត្យមើលឡើងវិញ និងកែលម្អក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ន ព្រមទាំងតួនាទីនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបំណុល ១២.២. រៀបចំនិងដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុល និង ១២.៣. បង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃការប្រើប្រាស់ទិន្នន័យបំណុល។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៨០% ក្នុងនោះ ចង្កោមសកម្មភាព ១២.១ សម្រេចបានតិចជាង ៥០%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៣ នៃចង្កោមសកម្មភាព នៃគោលបំណង ១២ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា មានសូចនាករ ២សម្រេចបានតាមគោលដៅគឺ÷

១. សេចក្តីព្រាងបច្ចុប្បន្នកម្មយុទ្ធសាស្ត្រគ្រប់គ្រងបំណុល ២០១៤-២០១៨ និងផែនការអភិវឌ្ឍន៍សមត្ថភាពស្ថាប័ននិងធនធានមនុស្សត្រូវបានរៀបចំ រួមទាំងរបាយការណ៍ស្តីពីការវិភាគចីរភាពបំណុល (DSA) ត្រូវបានធ្វើបច្ចុប្បន្នកម្ម

២. ប្រព័ន្ធគ្រប់គ្រងបំណុល DMFAS 6.0 ត្រូវបានតម្លើងរួចរាល់ និងបានបណ្តុះបណ្តាលមូលដ្ឋានគ្រឹះក្នុងការប្រើប្រាស់មុនផែនការអនុវត្តក្នុងត្រីមាសទី៤។

ដោយឡែក សូចនាករ ១ ដែលមិនសម្រេចបានតាមគោលដៅនោះ គឺ សេចក្តីព្រាងប្រកាសស្តីពីគោលការណ៍ និងនីតិវិធីគ្រប់គ្រងការឱ្យប្រាក់គេខ្ចី។ ការមិនសម្រេចបានតាមគោលដៅនេះ ដោយសារការយឺតយ៉ាវក្នុងការរៀបចំសេចក្តីព្រាងប្រកាសនេះ។

ដូចនេះ តាមរយៈសកម្មភាពនិងលទ្ធផលដែលសម្រេចបាន អាចសន្និដ្ឋានបានថា ការពង្រឹងការគ្រប់គ្រងបំណុលនៅតែរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ តែមិនទាន់អាចបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយទេ ពីព្រោះថាសុក្រឹតភាពនៃរបាយការណ៍វិភាគចីរភាពបំណុលនៅត្រូវការពង្រឹងបន្ថែម ដោយមូលហេតុកង្វះខាតទិន្នន័យមួយចំនួនសម្រាប់ធ្វើការវិភាគចីរភាពបំណុល សមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលនៅមានកម្រិត និង ក្របខ័ណ្ឌគតិយុត្តនិងក្របខ័ណ្ឌស្ថាប័ន ព្រមទាំងតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងបំណុលត្រូវការកែលម្អបន្ថែម។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តអភិវឌ្ឍន៍ស្ថាប័ននិងធនធានមនុស្សសម្រាប់ការគ្រប់គ្រងបំណុលសាធារណៈ និងបង្កើនសុក្រឹតភាពនៃការរៀបចំរបាយការណ៍វិភាគចីរភាពបំណុលដោយដោះស្រាយបញ្ហាប្រឈមនិងកង្វះខាតទិន្នន័យមួយចំនួនសម្រាប់ធ្វើការវិភាគចីរភាពបំណុល។

## ២.៣. ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី

ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី ដែលជាគោលបំណង ១៣ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មិនមានបម្រែបម្រួលពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណង ១៣ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មានចង្កោមសកម្មភាពចំនួន ៤ គឺ ពង្រឹងការគ្រប់គ្រងសាច់ ប្រាក់និងគណនី តាមរយៈចង្កោមសកម្មភាព ១៣.១. បន្តប្រមូលផ្តុំគណនីធនាគាររបស់រដ្ឋាភិបាលនិងពង្រឹងគណនីទោលរបស់រតនាគារ, ១៣.២. បន្តពង្រឹងនិងពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល និងចំណាយសាធារណៈ, ១៣.៣. ប្រមូលផ្តុំនិងបន្តកែលម្អផែនការសាច់ប្រាក់ (ពីប្រចាំត្រីមាស/ខែ ឈានទៅ ប្រចាំសប្តាហ៍/ថ្ងៃ) និង ១៣.៤. បន្តតាមដានបំណុលកកស្ទះនិងអាយុកាលរបស់វា។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៨៧% ក្នុងនោះចង្កោមសកម្មភាព ១៣.១ សម្រេចបាន ១០០%, ចង្កោមសកម្មភាព ១៣.២ សម្រេចបាន ៩៩%, ១៣.៣ សម្រេចបាន ៥០% និងចង្កោមសកម្មភាព ១៣.៤ សម្រេចបាន ១០០%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាព នៃគោលបំណង ១៣ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា មាន ៣ សូចនាករសម្រេចតាមគោលដៅ គឺ÷

១. គណនីក្រៅប្រព័ន្ធ TSA នៅធនាគារជាតិ និង ធនាគារពាណិជ្ជ ដែលមិនមានការអនុញ្ញាតពី កសហវ ត្រូវបានបិទ, គណនីទោលរតនាគារជាតិនៅរាជធានី ខេត្ត ត្រូវបានតាមដាននិងកំណត់ច្បាស់លាស់ និងគណនីគម្រោងរបស់ដៃគូអភិវឌ្ឍត្រូវបានប្រមូលចងក្រង

២. ការទូទាត់ថ្នាក់កណ្តាលតាមប្រព័ន្ធធនាគារ ១០០% និង ប្រព័ន្ធទូទាត់តាម E-Transfer ត្រូវបានសិក្សា និងគណនីប្រាក់បៀវត្សត្រូវបានតាមដានជាប្រចាំ

៣. អាណត្តិបើកប្រាក់ត្រូវបានតាមដាននិងបើកផ្តល់ឆាប់រហ័សនិងទាន់ពេលវេលា និង សមាហរណកម្មបំណុលកកស្ទះត្រូវបានសិក្សា។

ដោយឡែក សូចនាករមួយដែលមិនសម្រេចបានតាមគោលដៅ គឺ ការប្រមូលទិន្នន័យដើម្បីសាកល្បងរៀបចំផែនការសាច់ប្រាក់ប្រចាំថ្ងៃនិងសប្តាហ៍ និង ការពិនិត្យតាមដានការគ្រប់គ្រងសាច់ប្រាក់។ ការមិនសម្រេចបានតាមគោលដៅនេះដោយសារការព្យាករណ៍នៅពុំទាន់ខិតជិតនឹងចំណូល-ចំណាយជាក់ស្តែងនៅឡើយ ក្នុងគម្លាត +/-5% ឬ +/-10% និងដោយសារអង្គភាពពាក់ព័ន្ធពុំទាន់បានផ្តល់ព័ត៌មាននិងរបាយការណ៍តាមការស្នើសុំឱ្យបានទាន់ពេលវេលា។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ តែនៅមិនទាន់អាចបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយ ដោយហេតុថាសូចនាករត្រីមាសទី៣ នៃចង្កោមសកម្មភាព ១៣.៣ មិនបានសម្រេចតាមគោលដៅកំណត់ ជាក់ស្តែង ការព្យាករណ៍ចំណូល-ចំណាយពុំទាន់បានសុក្រឹត និងការផ្តល់ព័ត៌មាននិងរបាយការណ៍មានភាពយឺតយ៉ាវ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងពីភាពចាំបាច់ក្នុងការបន្តការកែលម្អនិងពង្រឹងការប្រមូលផ្តុំផែនការសាច់ប្រាក់ (ពីប្រចាំត្រីមាស/ខែ ឈានទៅប្រចាំសប្តាហ៍/ថ្ងៃ)។

## ២.៤. ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ

នៅក្នុង CAP 2 គោលបំណង ១៤ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា ផ្តោតលើការបន្តកែលម្អលទ្ធកម្មសាធារណៈ ដែលគោលបំណងដដែលនេះ ត្រូវបានកែសម្រួលមកជា ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយវិញ នៅក្នុង CAP 2 New។ រីឯក្នុងកម្រិតចង្កោមសកម្មភាព មានការតម្រឹមចំនួនចង្កោមសកម្មភាពពី ៦ មកត្រឹម ៣ តែប៉ុណ្ណោះ ដែលចង្កោមសកម្មភាពនីមួយៗ ក្នុង CAP 2 New នេះ។ គោលបំណង ១៤ ក្នុង CAP 2 New នេះមានវិសាលភាពគ្របដណ្តប់លើការពង្រឹងការអនុវត្តផែនការចំណាយ ធំជាង គោលបំណង ១៤ ក្នុង CAP 2 ដោយហេតុថា ក្នុង CAP 2 ការពង្រឹងការអនុវត្តផែនការចំណាយ ផ្តោតតែទៅលើការចំណាយពាក់ព័ន្ធលទ្ធកម្មសាធារណៈតែប៉ុណ្ណោះ។ រីឯ ក្នុង CAP 2 New ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ ផ្តោតតាំងពីការធានាចំណាយរហូតដល់ការទូទាត់ មិនត្រឹមតែក្នុងនីតិវិធីចំណាយលទ្ធកម្មសាធារណៈ តែថែមទាំងសម្រាប់ចំណាយក្រៅពីលទ្ធកម្មសាធារណៈផងដែរ ក្នុងគោលដៅធានានីតិវិធីខ្លី ដំណើរការលឿន និងមានប្រសិទ្ធភាព។

គោលបំណង ១៤ នៃផ្នែកភាពជឿទុកចិត្តបាននៃថវិកា មានចង្កោមសកម្មភាពចំនួន ៣ គឺផ្តោតលើការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ តាមរយៈចង្កោមសកម្មភាព ១៤.១. កែលម្អនិងពង្រឹងការអនុវត្តក្របខ័ណ្ឌគតិយុត្តស្តីពីលទ្ធកម្មសាធារណៈព្រមទាំងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃកិច្ចលទ្ធកម្មសាធារណៈ, ១៤.២. កែលម្អនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃកិច្ចដំណើរការផ្តល់ធានាចំណាយ និង ១៤.៣. កែលម្អនិងបង្កើនស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពនៃកិច្ចដំណើរការផ្តល់ការទូទាត់។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន ៦៤% ក្នុងនោះ ចង្កោមសកម្មភាព ១៤.១ សម្រេចបាន ៥៤%, ចង្កោមសកម្មភាព ១៤.២ សម្រេចបាន ៧៣% និង ១៤.៣ សម្រេចបាន ៦៥%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៣ នៃចង្កោមសកម្មភាព នៃគោលបំណង ១៤ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា សូចនាករទាំង៣នេះ មិនសម្រេចតាមគោលដៅ គឺ ១. សេចក្តីព្រាងអនុក្រឹត្យនិងប្រកាសនានាត្រូវបានពិនិត្យនិងពិភាក្សា និងសៀវភៅណែនាំស្តីពីលទ្ធកម្មត្រូវបានធ្វើបច្ចុប្បន្នភាព ២. សេចក្តីព្រាងគោល-

ការណ៍នៃការផ្តល់ធានាចំណាយសម្រាប់គម្រោងវិនិយោគនិងកម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈ ត្រូវបានរៀបចំ និង ការធានាចំណាយត្រូវបានអនុវត្តតាមផែនការចំណាយ និង ៣. បែបបទនៃការទូទាត់សម្រាប់គម្រោងវិនិយោគនិង កម្មវិធីថែទាំហេដ្ឋារចនាសម្ព័ន្ធសាធារណៈត្រូវបានរៀបចំ និងការទូទាត់ចំណាយត្រូវបានអនុវត្តតាមផែនការចំណាយ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការកែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ មិនអាចសម្រេចបានតាមគោលដៅកំណត់ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ នេះទេ ដោយហេតុថា ការរៀបចំសកម្មភាពនិងការកំណត់សូចនាករ មិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណងដែលបានកំណត់។

## ផ្នែកទី២: គណនេយ្យភាពហិរញ្ញវត្ថុ

នៅក្នុង CAP 2 ផ្នែកទី២ គណនេយ្យភាពហិរញ្ញវត្ថុ ត្រូវបានគាំទ្រដោយគោលបំណងចំនួន ៨ និង ចង្កោមសកម្មភាពចំនួន ៤៩ រីឯ នៅក្នុង CAP 2 New មានគោលបំណងចំនួន ៦ (២១. ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី, ២២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី, ២៣. ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព, ២៤. ការដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព, ២៥. ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា និង ២៦. ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច) និង ចង្កោមសកម្មភាពចំនួន ២៨។ ព្រមជាមួយគ្នានេះ ក្នុងគោលដៅបង្កើនល្បឿននៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការបញ្ចប់ដោយជោគជ័យនៃដំណាក់កាលទី២ គឺគណនេយ្យភាពហិរញ្ញវត្ថុនេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតនិងដាក់ឱ្យអនុវត្តយុទ្ធសាស្រ្ត ៣+២ នៅខែមីនា ឆ្នាំ២០១០។ យុទ្ធសាស្រ្ត ៣+២ នេះ ត្រូវបានគាំទ្រដោយ កត្តាលីករសំខាន់ៗចំនួន ៥ ដែលត្រូវអនុវត្តដោយអង្គភាព ចំនួន ៣ គឺ អគ្គនាយកដ្ឋានរតនាគារជាតិ នាយកដ្ឋានថវិកា (បច្ចុប្បន្ន អគ្គនាយកដ្ឋានថវិកា) និងនាយកដ្ឋានព័ត៌មានវិទ្យា។ កត្តាលីករទាំង៥ ត្រូវបានគាំទ្រដោយ កត្តាលីករគន្លឹះ៣ គឺ បន្ទាត់គណនេយ្យភាព ស្តង់ដារគណនេយ្យ និង ការអនុវត្តថវិកា បូកថែមកត្តាលីករគន្លឹះចំនួន ២ ទៀត គឺ ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង ការអភិវឌ្ឍន៍សមត្ថភាព។ ឆ្នាំ២០០៤ នេះ គឺជាឆ្នាំចុងក្រោយដែលត្រូវបញ្ចប់ការអនុវត្តយុទ្ធសាស្រ្ត ៣+២ ដែលផ្តោតលើការត្រៀមរៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ប្រតិបត្តិការរតនាគារ (Treasury Centric Module) និង ត្រូវចាប់ផ្តើមដាក់ឱ្យដំណើរការនៅដើមឆ្នាំ២០១៥។

ក្នុងផ្នែកនេះ ចំណុចខុសគ្នាពី CAP 2 គឺក្នុង CAP 2 New មានការដាក់ឱ្យអនុវត្តពេញលេញចំណាត់ថ្នាក់ថវិកាថ្មី យ៉ាងតិច ៣ ចំណាត់ថ្នាក់ គឺ សេដ្ឋកិច្ច ភូមិសាស្រ្ត និងរដ្ឋបាល។ ម្យ៉ាងទៀត ការបន្តកែលម្អភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា ដែលត្រូវបានអនុវត្តក្នុងគោលបំណង ៣២ នៃផ្នែកទី៣ នៃ CAP 2 ត្រូវបានកែសម្រួលមកជាគោលបំណង ២៥ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុនេះ។

ជារួម ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៦៤% ដែលក្នុងនោះគោលបំណងទី១ សម្រេចបាន ៧០%, គោលបំណងទី២ សម្រេចបាន ៨៣%, គោលបំណងទី៣ សម្រេចបាន ៤០%, គោលបំណងទី៤

សម្រេចបាន ៩%, គោលបំណងទី៥ សម្រេចបាន ១០០% និង គោលបំណងទី៦ សម្រេចបាន ៨០%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានទាបជាង ៥០% គឺ ចង្កោមសកម្មភាព ២១.៤, ២៣.២, ២៣.៣, ២៣.៤,២៤.១, ២៤.២, ២៤.៣, ២៤.៤, និង ២៦.៣។ ទន្ទឹមនេះ បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករ នៃគោលបំណងទាំង ៦ ដើម្បី ពង្រឹងនិងគាំទ្រដល់គណនេយ្យភាពហិរញ្ញវត្ថុ ជារួម គឺសម្រេចបានតាមគោលដៅនៃសូចនាករដែលបានកំណត់ ប៉ុន្តែ ចាំបាច់ត្រូវរៀបចំសកម្មភាពនិងសូចនាករដើម្បីគាំទ្រដល់ចង្កោមសកម្មភាពដែលមិនសម្រេចបានខាងលើ។

ដូច្នេះ ជារួម អាចសន្និដ្ឋានបានថាគណនេយ្យភាពហិរញ្ញវត្ថុ នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នេះ តែមិនទាន់បានបង្កើនទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយ។ លទ្ធផលនេះបានឆ្លុះបញ្ចាំង អំពីភាពចាំបាច់ជាពិសេស ក្នុងការពង្រឹងការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព ការដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាពក្នុងគោលដៅបន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ។

## ១. ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី

ការបន្តកែលម្អមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី ត្រូវបានអនុវត្តនៅក្នុងគោលបំណង ២៣ នៃផ្នែកគណនេយ្យ-ភាពហិរញ្ញវត្ថុ នៃ CAP 2 តាមរយៈការអនុវត្តចង្កោមសកម្មភាពចំនួន ៤។ ក្នុងគោលដៅបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ ការកសាងនិងដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី ដែលនៅមិនទាន់សម្រេចបានតាមការគ្រោងទុកនៅក្នុង CAP 2 នៅតែបន្តអនុវត្តក្នុងផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ (គោលបំណង ២១) នៃ CAP 2 New។ រវាង CAP 2 និង CAP 2 New មានភាពប្លែកគ្នាត្រង់ ការដាក់ឱ្យអនុវត្តពេញលេញចំណាត់ថ្នាក់ថវិកាថ្មី យ៉ាងតិច ៣ ចំណាត់ថ្នាក់ គឺ សេដ្ឋកិច្ច ភូមិសាស្ត្រ និងរដ្ឋបាល។

ដើម្បីសម្រេចបានតាមការកំណត់ ចង្កោមសកម្មភាពចំនួន៤ ត្រូវបានដាក់ឱ្យអនុវត្ត គឺ ២១.១. ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនេយ្យថ្មី, ២១.២. ត្រួតពិនិត្យឡើងវិញនិងបន្តកែលម្អចំណាត់ថ្នាក់ថវិកាថ្មីដើម្បីដាក់អនុវត្តឱ្យពេញលេញយ៉ាងតិច ៤ គឺ ចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិ និងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច និង ២១.៣. សិក្សានិងផ្តល់ជម្រើសចំណាត់ថ្នាក់មុខងារ មូលនិធិ និងគម្រោង ២១.៤ សិក្សានិងផ្តល់ជម្រើសសម្រាប់ការឈានទៅប្រព័ន្ធគណនេយ្យ បង្ករជាជំហានៗ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន ៧០%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានតិចជាង ៥០% នៃគោលដៅគឺចង្កោមសកម្មភាព ២១.៤។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាព នៃគោលបំណង ២១ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា មានសូចនាករ៣ សម្រេចបានតាមគោលដៅគឺ៖

១. ភាពខុសគ្នានិងដូចគ្នារវាង CoA និង TOFE ត្រូវបានសិក្សា, ភាពខុសគ្នានិងដូចគ្នារវាង CoA និង GFS ត្រូវបានសិក្សានិងកំណត់តម្រូវការក្នុងការធ្វើទំនាក់ទំនង និង មាតិកាគណនីថ្មីត្រូវបានផ្សព្វផ្សាយ ដើម្បីត្រៀមអនុវត្តនៅឆ្នាំ២០១៥

២. ចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច ត្រូវបានពិនិត្យឡើងវិញនិងកែលម្អ

៣. ជម្រើសចំណាត់ថ្នាក់កម្មវិធី មុខងារ និងប្រភពធនធាន ត្រូវបានសិក្សា។

ដោយឡែកសូចនាករ ១ ដែលមិនសម្រេចបានតាមគោលដៅនោះ គឺ របាយការណ៍តាមស្តង់ដារ IPSAS Cash Basis ត្រូវបានរៀបចំសាកល្បង។ ការមិនសម្រេចតាមគោលដៅនេះ ដោយសារ កង្វះជំនាញការដើម្បីសិក្សានិងផ្តល់ជម្រើសសម្រាប់ការអនុវត្តសាកល្បងប្រព័ន្ធគណនេយ្យបង្គរជាជំហានៗ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ក៏ប៉ុន្តែនៅមិនទាន់សម្រេចបានតាមគោលដៅដែលចង់បាននៅឡើយ ដោយហេតុថាសូចនាករត្រីមាសទី៣ នៃចង្កោមសកម្មភាព ២១.៤ មិនបានសម្រេចតាមគោលដៅកំណត់ ដោយសារកង្វះជំនាញការ ដើម្បីសិក្សានិងផ្តល់ជម្រើសសម្រាប់ការអនុវត្តសាកល្បងប្រព័ន្ធគណនេយ្យបង្គរជាជំហានៗ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តកែលម្អប្លង់គណនេយ្យថ្មីនិងចំណាត់ថ្នាក់ថវិកាថ្មី ដើម្បីដាក់អនុវត្តឱ្យពេញលេញយ៉ាងតិច៤ គឺ ចំណាត់ថ្នាក់ភូមិសាស្ត្រ អង្គភាពប្រតិបត្តិនិងរដ្ឋបាល កម្មវិធី និងសេដ្ឋកិច្ច និងសិក្សាដាក់ឱ្យអនុវត្តបន្ថែមចំណាត់ថ្នាក់មុខងារ មូលនិធិ និងគម្រោង និងជ្រើសរើសជំនាញការឱ្យទាន់ពេលវេលា ដើម្បីបន្តសិក្សានិងផ្តល់ជម្រើសសម្រាប់ការអនុវត្តសាកល្បងប្រព័ន្ធគណនេយ្យបង្គរជាជំហានៗ។

## ២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី

ការកែលម្អដំណើរការនិងប្រតិបត្តិការអនុវត្តថវិកា ដែលត្រូវបានអនុវត្តក្នុងគោលបំណង ២៤ នៃ CAP 2 ត្រូវបានកែសម្រួលមកជាគោលបំណង ២២. ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី ក្នុង CAP 2 New។ គោលបំណងនេះ ផ្តោតជាពិសេសដល់ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS។ ម្យ៉ាងទៀត ចង្កោមសកម្មភាពនៃគោលបំណងនេះ មានចំនួន ៨ ក្នុង CAP 2 ត្រូវតម្រឹមមក ចំនួន ៧ ក្នុង CAP 2 New ដែលរួមមាន÷ ២២.១. បន្តកាត់បន្ថយពេលវេលាសម្រាប់ការស្នើសុំធានាចំណាយនិងការទូទាត់នៅក្នុងក្រសួង-ស្ថាប័ន ២២.២. កែលម្អដំណើរការនៃប្រតិបត្តិការនៅក្នុងកសហវ/ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនេយ្យ និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ ២២.៣. បង្កើនកម្រិតយល់ដឹងភាពជាម្ចាស់ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ២២.៤. កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅ កសហវ ក្រសួង ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ២២.៥. រៀបចំផែនការអនុវត្តរួម (ការសាកល្បងនិងការពង្រីក) ដោយរួមបញ្ចូល កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ ២២.៦. រៀបចំផែនការ និងវគ្គបណ្តុះបណ្តាល ព្រមទាំងឯកសារបណ្តុះបណ្តាលសម្រាប់ការបន្តបណ្តុះបណ្តាលដល់គ្រប់មន្ត្រីដែលពាក់ព័ន្ធនឹង FMIS នៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ និង ២២.៧. ការអនុវត្តសាកល្បងជំហានដំបូងនិងពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូលនិងម៉ូឌុលសម្រាប់ថវិកា)។

ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះ សម្រេចបាន ៨៣% ដោយក្នុងនោះ ចង្កោមសកម្មភាព ២២.១. សម្រេចបាន ៦៦%, ចង្កោមសកម្មភាព ២២.២. សម្រេចបាន ៧៥%, ចង្កោមសកម្មភាព ២២.៣.

សម្រេចបាន ១០០%, ចង្កោមសកម្មភាព ២២.៤. សម្រេចបាន ៧៥%, ចង្កោមសកម្មភាព ២២.៥. សម្រេចបាន ៩៣ %, ចង្កោមសកម្មភាព ២២.៦. សម្រេចបាន ១០០% និងចង្កោមសកម្មភាព ២២.៧. សម្រេច បាន ៦៩%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៧ នៃចង្កោមសកម្មភាព នៃគោលបំណងទី២ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា សូចនាករទាំង ៧ នេះ សម្រេចតាមគោលដៅ គឺ÷

១. សេម៉ាបរិបទចំណាយបច្ចុប្បន្នត្រូវបានរៀបចំ

២. ស្តង់ដារនៃការអនុវត្តថវិកានៃបណ្តាប្រទេសផ្សេងៗ តាមរយៈ PEMNA ដើម្បីបន្តពង្រឹងការងារអនុវត្តថវិកាស្រប តាមស្តង់ដារអន្តរជាតិ ត្រូវបានសិក្សា

៣. សមត្ថភាពផ្នែក FMIS របស់មន្ត្រី កសហវ ត្រូវបានបង្កើន តាមរយៈការផ្សព្វផ្សាយទូលំទូលាយ លើគេហទំព័រ និងព្រឹត្តបត្រព័ត៌មាន ការជួបសម្ភាសផ្ទាល់ ការរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងការបណ្តុះបណ្តាល

៤. សមត្ថភាពមន្ត្រីគ្រប់គ្រងគម្រោង FMIS ផ្នែកគ្រប់គ្រងមូលដ្ឋានទិន្នន័យ (Database) ត្រូវបានពង្រីកបន្ថែម

៥. សេចក្តីព្រាងផែនការអនុវត្តប្រព័ន្ធ FMIS រួម សម្រាប់ដំណាក់កាលទី១ ត្រូវបានរៀបចំ

៦. សេចក្តីព្រាងផែនការបណ្តុះបណ្តាលរួមសម្រាប់គម្រោង FMIS ដំណាក់កាលទី១ ត្រូវបានកែលម្អ

៧. បន្ទប់សម្រាប់បណ្តុះបណ្តាលប្រព័ន្ធ FMIS ត្រូវបានរៀបចំ, សេចក្តីព្រាងឯកសារនីតិវិធីអនុវត្តការងារអនាគត ត្រូវបានរៀបចំ និងសេចក្តីព្រាងឯកសារវាយតម្លៃផលប៉ះពាល់ត្រូវបានរៀបចំ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ផ្អែកលើសកម្មភាពនិងសូចនាករដែលបានកំណត់ក្នុងផែនការសកម្មភាព ដំណាក់កាលទី២ ថ្មី របស់អគ្គនាយកដ្ឋាន/អង្គភាព ការដាក់ឱ្យអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី អាចរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ប៉ុន្តែ ជាក់ស្តែង ការរៀបចំសូចនាករទី៧ ខាងលើ (ដូចជាសេចក្តីព្រាងឯកសារនីតិវិធីអនុវត្តការងារអនាគតត្រូវបានរៀបចំ និង សេចក្តីព្រាងឯកសារវាយតម្លៃផលប៉ះពាល់ត្រូវបានរៀបចំ) មិនត្រូវតាមពេលវេលាកំណត់ ព្រោះថាក្នុងត្រីមាសទី៣នេះ យ៉ាងហោចណាស់ នីតិវិធីអនុវត្តការងារអនាគត (To-Be Business Process), យុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងការផ្លាស់ប្តូរ (Change Management Strategy) និងឯកសារវាយតម្លៃផលប៉ះពាល់សម្រាប់គម្រោង FMIS គួរត្រូវបានរៀបចំឱ្យបានរួចរាល់ក្នុងអំឡុងដើមត្រីមាសទី៣ ឆ្នាំ២០១៤ ដើម្បីឈានទៅរៀបចំនិងដាក់ឱ្យអនុវត្ត (Go Live) គម្រោង FMIS បាននៅខែកក្កដា ឆ្នាំ២០១៥ ដូចដែលបានកំណត់។ ប៉ុន្តែ ការដាក់ឱ្យអនុវត្ត Go Live មិនអាចសម្រេចទៅបាន ដោយហេតុថា ចំណុចទាំងបីនេះខាងលើនេះ មិនទាន់បានរៀបចំរួចរាល់នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ នេះទេ និងម្យ៉ាងទៀតដោយសារសមត្ថភាពរបស់ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS Contractor) នៅមានកម្រិត។ ដូចនេះ ដើម្បីអាចរៀបចំនិងដាក់ឱ្យអនុវត្ត (Go Live) នេះបានតាមពេលវេលាកំណត់ គួររៀបចំឱ្យមានការត្រួតពិនិត្យឡើងវិញលើគម្រោង FMIS។

## ៣. ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព

ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព ដែលជាគោលបំណង ២៣ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ មិនមានបម្រែបម្រួលពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណងនេះ មានចង្កោមសកម្មភាពអនុវត្តចំនួន ៥ គឺផ្តោតទៅលើការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព តាមរយៈចង្កោមសកម្មភាព ២៣.១. ការពិនិត្យឡើងវិញនូវស្តង់ដារគណនេយ្យ រដ្ឋបាលសាធារណៈ ដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAPP) និងវាយតម្លៃភាពប្រាកដនិយម និងភាពសមស្របនៃលំដាប់លំដោយក្នុងការដាក់ឱ្យអនុវត្តស្តង់ដារគណនេយ្យនេះ ដោយផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS, ២៣.២. ដាក់ឱ្យអនុវត្តនូវរបាយការណ៍អនុវត្តថវិកាប្រចាំ ត្រីមាសដែលបញ្ជាក់អំពីការងារដែលបានបំពេញធៀបនឹងគោលដៅ លទ្ធផលទទួលបាន ការយឺតយ៉ាវ និង វិធានការដោះស្រាយ÷ ពីក្រសួង-ស្ថាប័ន មក កសហវ និងនៅផ្ទៃក្នុងក្រសួង-ស្ថាប័ន ពីអង្គភាពថវិការហូតដល់ ថ្នាក់ ដឹកនាំ, ២៣.៣. កែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅគណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិប្បញ្ញត្តិ, ២៣.៤. កែលម្អទម្រង់របាយការណ៍និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន និង ២៣.៥. ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋនិងធ្វើបច្ចុប្បន្នភាពជាប្រចាំ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៤០% ក្នុងនោះចង្កោមសកម្មភាព ២៣.១ និង ២៣.៥ សម្រេចបាន១០០% ប៉ុន្តែចង្កោមសកម្មភាព ៣ ទៀត គឺ ចង្កោមសកម្មភាព ២៣.២, ២៣.៣ និង ២៣.៤ មិនមានសកម្មភាពអនុវត្តទេ។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៥ នៃចង្កោមសកម្មភាព នៃគោលបំណងទី៣ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា សូចនាករទាំង ៥ សម្រេចបានតាមគោលដៅចំនួន ២ គឺ÷

១. ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋានសាច់ប្រាក់ ត្រូវបានរៀបចំ

២. សេចក្តីព្រាងសារាចរណែនាំស្តីពីបញ្ជីសារពើភ័ណ្ឌត្រូវបានអនុម័តដោយ គ.ម.រ។

ដោយឡែក សូចនាករ ៣ ទៀត មិនអាចធ្វើការវាស់វែងបាន ដោយហេតុថា អគ្គនាយកដ្ឋានពាក់ព័ន្ធពុំបានរៀបចំសកម្មភាពនិងសូចនាករដើម្បីគាំទ្រដល់ចង្កោមសកម្មភាពនិងសូចនាករទាំងបីខាងលើទេ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព មិនទាន់អាចធានានិងរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នៅឡើយទេ ដោយហេតុថា សកម្មភាពដែលអនុវត្តគាំទ្រដល់ការសម្រេចបាននូវចង្កោមសកម្មភាព ២៣.២, ២៣.៣ និង ២៣.៤ ដែលបានកំណត់ ពុំត្រូវបានរៀបចំ។ តាមរយៈលទ្ធផលនេះ អគ្គនាយកដ្ឋានពាក់ព័ន្ធចាំបាច់ត្រូវរៀបចំសកម្មភាពដើម្បីគាំទ្រដល់ចង្កោមសកម្មភាព

២៣.២, ២៣.៣ និង ២៣.៤ ក្នុងគោលបំណងអាចដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព ដូចបានកំណត់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។

## ៤. ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព

ការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព ដែលជាគោលបំណង ២៤ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ មិនមានភាពខុសគ្នា ពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណងទី៤ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ មានចង្កោមសកម្មភាពចំនួន ៣ គឺផ្ដោតទៅលើការដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព តាមរយៈចង្កោមសកម្មភាព ២៤.១. បង្កើតឱ្យមានទណ្ឌកម្មសមស្របចំពោះកំហុសឆ្គង ឬ ការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងច្បាប់និងធ្វើការផ្សព្វផ្សាយនិងណែនាំឱ្យបានទូលំទូលាយ, ២៤.២. រៀបចំឱ្យមានតារាងបញ្ជាក់អំពីសិទ្ធិអំណាច និងភាពទន់ភ្លន់ដែលនឹងផ្ដល់ជូនអង្គភាពថវិកាដែលបានបំពេញលក្ខណៈវិនិច្ឆ័យ ដែលមានការឯកភាពសម្រាប់ប្រព័ន្ធគ្រប់គ្រងធនធានសាធារណៈដ៏ត្រឹមត្រូវ, ២៤.៣. ធ្វើការត្រួតពិនិត្យឡើងវិញជាប្រចាំលើលទ្ធផលនៃការគ្រប់គ្រងធនធានដែលសម្រេចបានដោយអង្គភាពថវិកានីមួយៗ ដើម្បីធ្វើជាមូលដ្ឋានក្នុងការពង្រីកការផ្ដល់សិទ្ធិអំណាចនិងភាពទន់ភ្លន់ និង ២៤.៤. ដាក់ឱ្យអនុវត្តនូវរបាយការណ៍អនុវត្តថវិកាប្រចាំត្រីមាស ដែលបញ្ជាក់អំពីការងារដែលបានបំពេញធៀបនឹងគោលដៅលទ្ធផល ទទួលបានការយឺតយ៉ាវនិងវិធានការដំណោះស្រាយ÷ ពីក្រសួង-ស្ថាប័ន មក កសហវ និងនៅផ្ទៃក្នុងក្រសួងស្ថាប័ន ពីអង្គភាពថវិការហូតដល់ថ្នាក់ដឹកនាំ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៩% ប៉ុន្តែចង្កោមសកម្មភាព ៣ ទៀត គឺ ចង្កោមសកម្មភាព ២៤.២, ២៤.៣ និង ២៤.៤ មិនមានសកម្មភាពអនុវត្តទេ។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាព នៃគោលបំណងទី៤ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាមិនអាចធ្វើការវាស់វែងបាន ដោយហេតុថា អគ្គនាយកដ្ឋានថវិកាពុំបានរៀបចំសកម្មភាពនិងសូចនាករដើម្បីគាំទ្រដល់ចង្កោមសកម្មភាពនិងសូចនាករទាំង ៤ ខាងលើទេ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព មិនទាន់អាចធានានិងរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នៅឡើយទេ ដោយហេតុថា សកម្មភាពដែលអនុវត្តគាំទ្រដល់ការសម្រេចបាននូវចង្កោមសកម្មភាព ២៤.២, ២៤.៣ និង ២៤.៤ ដែលបានកំណត់ ពុំត្រូវបានរៀបចំ។ តាមរយៈលទ្ធផលនេះ អគ្គនាយកដ្ឋានពាក់ព័ន្ធចាំបាច់ត្រូវរៀបចំសកម្មភាពដើម្បីគាំទ្រដល់ចង្កោមសកម្មភាព ២៤.២, ២៤.៣ និង ២៤.៤ ក្នុងគោលបំណងអាចដាក់ឱ្យអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព ដូចបានកំណត់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។

## ៥. ពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា

ការបន្តកែលម្អភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា ត្រូវបានអនុវត្តក្នុងគោលបំណង ៣២ នៃផ្នែកទី៣ គឺ សកម្មភាពសម្រាប់ជំហានបន្ទាប់ នៃ CAP 2 តាមរយៈការអនុវត្តចង្កោមសកម្មភាពចំនួន២។ ដោយហេតុថាគោលបំណងនេះ នៅមិនទាន់សម្រេចបានតាមគោលដៅកំណត់នៅឡើយ គោលបំណងនេះនៅត្រូវការអនុវត្តក្នុង CAP 2 New ជាបន្តទៀត។

គោលបំណងនេះ ចង្កោមសកម្មភាពចំនួន២ ត្រូវបានបន្តអនុវត្តគឺ ចង្កោមសកម្មភាព ២៥.១. រៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្មថវិកា, បន្តកែលម្អការធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធន តាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSP) និងថវិកាតាមកម្មវិធី (BP), ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយេនឌ័រទៅក្នុងគោលការណ៍ណែនាំស្តីពីផែនការយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី និង ២៥.២. បន្តបញ្ចូលចំណូលចំណាយដែលនៅក្រៅបរិបថថវិកាទៅក្នុងថវិកាប្រចាំឆ្នាំរួមទាំងការបង្កើនជាបណ្តើរៗនូវការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន ១០០% ក្នុងនោះសកម្មភាពនៃចង្កោមសកម្មភាព ២៥.១ ដែលបានរៀបចំ ពុំទាន់ដល់ពេលអនុវត្ត និងចង្កោមសកម្មភាព ២៥.២ សម្រេចបាន ១០០% ដែលមានសូចនាករ គឺ ផែនការកែលម្អទិន្នន័យហិរញ្ញប្បទានត្រូវបានរៀបចំ។

ដូចនេះ តាមរយៈសកម្មភាពនិងលទ្ធផលដែលសម្រេចបាន អាចសន្និដ្ឋានបានថា ការពង្រឹងនិងបង្កើនភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកា នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ដើម្បីធានាសង្គតិភាពនិងភាពគ្រប់ជ្រុងជ្រោយនៃថវិកាតាមគោលដៅកំណត់ ប៉ុន្តែនៅមិនទាន់សម្រេចបានភាពគ្រប់ជ្រុងជ្រោយនិងសមាហរណកម្មថវិកាពេញលេញនៅឡើយទេ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលអគ្គនាយកដ្ឋានពាក់ព័ន្ធ ត្រូវបន្តខិតខំក្នុងការអនុវត្តចង្កោមសកម្មភាពទាំងពីរ ប្រកបដោយប្រសិទ្ធភាព ជាពិសេសការធ្វើសមាហរណកម្មថវិកាចរន្តនិងមូលធននិងការបញ្ចូលមូលនិធិពីដៃគូអភិវឌ្ឍន៍ទៅក្នុងថវិកាប្រចាំឆ្នាំ។

## ៦. ពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច

ការពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច ដែលជាគោលបំណង ២៦ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ មិនមានភាពខុសគ្នា ពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណង ២៦ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ បានកំណត់ដាក់ចេញនូវចង្កោមសកម្មភាពចំនួន៤ ដោយផ្តោតយកចិត្តដាក់ជាអាទិភាពទៅលើការពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច តាមរយៈចង្កោមសកម្មភាព ២៦.១. ដំណើរការពេញលេញអង្គភាពសវនកម្មផ្ទៃនៅគ្រប់ក្រសួង-ស្ថាប័ន, ២៦.២. កែលម្អយន្តការដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងលទ្ធផលសវនកម្ម និងអធិការកិច្ចនៅតាមបណ្តាអង្គភាពថវិកា, ២៦.៣. រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យវាយតម្លៃហានិភ័យដែលបានផ្តល់អនុសាសន៍ដោយ កសហវ និង ២៦.៤. កសហវ ពិនិត្យមើលឡើងវិញពីភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/ អធិកា

វកិច្ចនិងធ្វើការកែលម្អ។ ជារួម ផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ៨០%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចទាបជាង ៥០% គឺចង្កោមសកម្មភាព ២៦.៣។

ទន្ទឹមនេះ បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករទាំង ៤ នៃចង្កោមសកម្មភាពនៃគោលបំណង ២៦ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាសូចនាករ ៣ សម្រេចបានតាមគោលដៅ គឺ÷

១. អង្គភាពសវនកម្មនៅតាមក្រសួង-ស្ថាប័ន ដែលពុំទាន់បង្កើត ត្រូវបានរៀបចំស្របតាមនីតិវិធី/លក្ខណៈវិនិច្ឆ័យ សមស្របតាមការណែនាំរបស់អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង នៃ កសហវ

២. យន្តការនិងនីតិវិធីសម្រាប់ប្រឹក្សាយោបល់និងកែលម្អរបាយការណ៍សវនកម្មនិងអធិការកិច្ចក្រសួងស្ថាប័ន ត្រូវបានបង្កើតនិងអនុវត្ត

៣. ផែនការសវនកម្មនិងអធិការកិច្ចប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន ត្រូវបានរៀបចំ

ដោយឡែក សម្រាប់សូចនាករនៃចង្កោមសកម្មភាព ២៦.២ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ ពិបាកធ្វើការវាស់វែងតាមដានអនុវត្ត ដោយហេតុថា សូចនាករនៃសកម្មភាព ដែលបានរៀបចំដើម្បីគាំទ្រដល់ចង្កោមសកម្មភាពនេះ ពុំទាន់មានភាពគ្រប់គ្រាន់ សុក្រឹតភាព និងសង្គតិភាព។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថាការពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអធិការកិច្ច នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ តែនៅមិនទាន់ឈានទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយ។ លទ្ធផលនេះ បានឆ្លុះបញ្ចាំងអំពីតម្រូវការចាំបាច់ក្នុងការបន្តរៀបចំដំណើរការពេញលេញអង្គភាពសវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួង ស្ថាប័ន, រៀបចំនិងកែលម្អផែនការសវនកម្ម/អធិការកិច្ចប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន, ការពិនិត្យមើលឡើងវិញពីភាពគ្រប់គ្រាន់នៃគំរូរបាយការណ៍សវនកម្ម/អធិការកិច្ច និងជាពិសេស ការកែលម្អយន្តការដើម្បីធានាការឆ្លើយតបប្រកបដោយប្រសិទ្ធភាពនិងលទ្ធផលសវនកម្មនិងអធិការកិច្ចនៅតាមបណ្តាអង្គភាពថវិកា។

## ផ្នែកទី៣: ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់

ផ្នែកទី៣ ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ក្នុង CAP 2 New ត្រូវបានគាំទ្រដោយគោលបំណងចំនួន ៤ និង ចង្កោមសកម្មភាពចំនួន ១៩ និង ក្នុង CAP 2 ដោយគោលបំណងចំនួន ២ និងចង្កោមសកម្មភាពចំនួន ៥។ គោលបំណងទាំង ៤ រួមមាន ៣១. ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី, ៣២. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ រវាង កសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង-ស្ថាប័ន), ៣៣. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ និង ៣៤. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។ ក្នុងចំណោមគោលបំណងទាំង ៤ ក្នុង CAP 2 New មានតែគោលបំណង ៣១ តែមួយគត់ ដែលមិនខុសគ្នាពី CAP 2។ ក្រៅពីនេះ គោលបំណង ៣២ ត្រូវបានបង្កើតថ្មី ដើម្បីគាំទ្រដល់ដំណើរការនៃការអនុវត្តថវិកាកម្មវិធីពេញលេញ និង ការដាក់ឱ្យអនុវត្តអង្គភាពថវិកា នៃក្រសួងទាំង១០ នៅឆ្នាំ២០១៥, គោលបំណង ៣៣ ក៏ត្រូវបានបង្កើតថ្មីដែរ ក្នុងគោលដៅពង្រឹងការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលវែង។ ដោយឡែក គោលបំណង៣៤ អំពីការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រវិមជ្ឈការ

ហិរញ្ញវត្ថុ ត្រូវបានផ្លាស់ប្តូរទីតាំង ពីផ្នែកទី២ នៃ CAP 2 មកស្ថិតនៅក្នុងផ្នែកទី៣ នៃ CAP 2 New គឺការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ដើម្បីឈានទៅអនុវត្ត ដំណាក់កាលទី៣ គឺការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយដោយផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

ជារួម ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៧៥% ដែលក្នុងនោះគោលបំណងទី១ សម្រេចបាន ៦៥%, គោលបំណងទី២ សម្រេចបាន៧០%, គោលបំណងទី៣ សម្រេចបាន៨៣% និង គោលបំណងទី៤ សម្រេចបាន ៨០%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានទាបជាង ៥០% គឺ ចង្កោមសកម្មភាព ៣១.១, ៣២.២, ៣២.៤ និង ៣៤.៦។ ទន្ទឹមនេះ បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករ នៃគោលបំណងទាំង៤ ដើម្បីពង្រឹងនិងគាំទ្រដល់ការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ជារួម គឺសម្រេចបានតាមគោលដៅនៃសូចនាករដែលបានកំណត់ ប៉ុន្តែ ចាំបាច់ត្រូវរៀបចំសកម្មភាពនិងសូចនាករដើម្បីគាំទ្រដល់ចង្កោមសកម្មភាពដែលមិនសម្រេចបានខាងលើ។

ដូច្នេះ ជារួម អាចសន្និដ្ឋានបានថាការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ នៅតែរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤នេះ តែមិនទាន់សម្រេចបានតាមគោលដៅដែលចង់បាននៅឡើយ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ ជាពិសេស ក្នុងការពង្រឹងការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិរវាង កសហវ និងក្រសួង-ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង-ស្ថាប័ន) និង ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ ក្នុងគោលដៅធានាឱ្យបាននូវការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ប្រកបដោយជោគជ័យនិងចីរភាព។

## ១. ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធី

ការពង្រឹងនិងពង្រីកការអនុវត្តថវិកាតាមកម្មវិធីដែលជាគោលបំណង ៣១ នៃផ្នែកការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ មិនមានភាពខុសគ្នា ពី CAP 2 ទេ ទាំងកម្រិតគោលបំណងនិងកម្រិតចង្កោមសកម្មភាព។

គោលបំណងទី១ នៃផ្នែកត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ មានចង្កោមសកម្មភាពអនុវត្តចំនួន ២ គឺ÷ ៣១.១. ពិនិត្យឡើងវិញនិងកែលម្អការអនុវត្តថវិកាតាមកម្មវិធី, ៣១.២. រៀបចំយុទ្ធសាស្ត្រដើម្បីពង្រីកថវិកាតាមកម្មវិធី និង ៣១.៣. អនុវត្តផែនការបណ្តុះបណ្តាលនិងការកសាងសមត្ថភាពសម្រាប់អនុវត្តថវិកាតាមកម្មវិធី។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន ៦៥% ក្នុងនោះសកម្មភាពនៃចង្កោមសកម្មភាព ៣១.២ ដែលបានរៀបចំ ពុំទាន់ដល់ពេលអនុវត្ត។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានទាបជាង៥០% គឺចង្កោមសកម្មភាព ៣១.១។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៣ នៃចង្កោមសកម្មភាព នៃគោលបំណងទី១ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាមាន ១ សូចនាករ សម្រេចបានតាមគោលដៅ គឺ ឯកសារបង្រៀននៃថវិកាកម្មវិធី ត្រូវធ្វើបច្ចុប្បន្នភាព ដើម្បីអនុវត្តផែនការបណ្តុះបណ្តាល និងការកសាងសមត្ថភាពសម្រាប់អនុវត្តថវិកាតាមកម្មវិធី។

ដោយឡែក សូចនាករនៃចង្កោមសកម្មភាព ៣១.១ មិនសម្រេចតាមគោលដៅ គឺ សេចក្តីព្រាងគោលការណ៍ណែ-នាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធី ត្រូវបានរៀបចំ។ ការមិនសម្រេចតាមគោលដៅនេះ ដោយសារការរៀបចំសកម្មភាពនិងការកំណត់សូចនាករមិនមានសុក្រឹតភាព (ពេលវេលាមិនគ្រប់គ្រាន់) និងម្យ៉ាងទៀត សូចនាករនៃចង្កោមសកម្មភាព ៣១.២ មិនទាន់ដល់ពេលអនុវត្ត។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី នៅតែរក្សាបានសម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ប៉ុន្តែនៅមិនទាន់បានឈានទៅរកគោលដៅដែលចង់បាននៅឡើយ ដោយសារភាពយឺតយ៉ាវនៃការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការពង្រឹងការរៀបចំគោលការណ៍ណែនាំស្តីពីនីតិវិធីប្រតិបត្តិការចំណាយថវិកាតាមកម្មវិធី ដើម្បីដាក់ឱ្យថ្នាក់ដឹកនាំអនុម័តនៅចុងឆ្នាំ២០១៤ ទាន់ពេលវេលា។

## ២. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាង កសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន)

គោលបំណង ៣២ ត្រូវបានបង្កើតថ្មី ក្នុង CAP 2 New ដើម្បីគាំទ្រដល់ដំណើរការនៃការអនុវត្តថវិកាកម្មវិធីពេញលេញ និង ការដាក់ឱ្យអនុវត្តអង្គភាពថវិកា នៃក្រសួងទាំង១០ នៅឆ្នាំ២០១៥។

គោលបំណងនេះ មានចង្កោមសកម្មភាពចំនួន ៦ ដោយផ្តោតទៅលើការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព តាមរយៈចង្កោមសកម្មភាព ៣២.១. ពិនិត្យឡើងវិញនិងធ្វើវិសោធនកម្មលើច្បាប់និងបទបញ្ញត្តិដែលកំណត់ពីតួនាទីនិងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រដ្ឋាភិបាល, ៣២.២. កំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំនិងក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ និងកំណត់ពីការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងក្រសួង-ស្ថាប័ននីមួយៗ រួមមាន កសហវ ក្រសួង ផែនការនិងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា, ៣២.៣. កំណត់អង្គភាពថវិកានិងអ្នកគ្រប់គ្រងថវិកានៅរដ្ឋបាលថ្នាក់ជាតិនិង ថ្នាក់ក្រោមជាតិ, ៣២.៤. កំណត់ពីការទទួលខុសត្រូវនៃការគ្រប់គ្រងនៅគ្រប់កម្រិត, ៣២.៥. រៀបចំនិងចេញផ្សាយ កម្រង នីតិវិធីណែនាំដែលពន្យល់ពីការផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវដល់អង្គភាពថវិកានិងអ្នកគ្រប់គ្រងថវិកាហើយផ្សព្វផ្សាយតាមរយៈវគ្គបណ្តុះបណ្តាលនិងសិក្ខាសាលា និង ៣២.៦. កែសម្រួលរចនាសម្ព័ន្ធស្ថាប័នឱ្យឆ្លើយតបទៅនឹង ប្រព័ន្ធដំណើរការការងារថ្មីដែលត្រូវបានបង្កើតរួមទាំងការបន្តបញ្ជូនមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅតាមក្រសួង-ស្ថាប័ន ដោយ កំណត់ឱ្យបានច្បាស់ពីតួនាទីនៅក្នុងក្របខ័ណ្ឌវិមជ្ឈការ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន៧០% ក្នុងនោះចង្កោមសកម្មភាព ៣២.១. ដែលបានរៀបចំ ពុំទាន់ដល់ពេលអនុវត្ត។ ដោយឡែក សកម្មភាពនៃចង្កោមសកម្មភាព ៣២.២. និង ចង្កោមសកម្មភាព ៣២.៤. មិនត្រូវបានរៀបចំ។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៦ នៃចង្កោមសកម្មភាពនៃគោលបំណងទី២ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថា មាន ២ សូចនាករ សម្រេចបានតាមគោលដៅ គឺ

១. ក្រុមការងារសម្រាប់រៀបចំសិក្សាមុខចំណាយត្រូវធ្វើប្រតិភូកម្មដល់មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ក្នុងការចុះទិដ្ឋាការលើលិខិតធានាចំណាយនិងអាណត្តិបើកប្រាក់ ត្រូវបានបង្កើត

២. គោលការណ៍វាយតម្លៃដើម្បីកំណត់អង្គភាពថវិកាដល់ក្រសួង ស្ថាប័នអនុវត្តថវិកាកម្មវិធីត្រូវបានរៀបចំ។

ដោយឡែក សូចនាករនៃចង្កោមសកម្មភាព ៤ ទៀត មិនទាន់សម្រេចបានតាមគោលដៅ ដោយហេតុថា សូចនាករនៃចង្កោមសកម្មភាព ៣២.១. ដែលបានរៀបចំ ពុំទាន់ដល់ពេលអនុវត្ត, សូចនាករនៃចង្កោមសកម្មភាព ៣២.២ និង ៣២.៤ មិនអាចធ្វើការវាស់វែងបាន ដោយសកម្មភាពនិងសូចនាករ ពុំត្រូវបានរៀបចំ និងសូចនាករនៃចង្កោមសកម្មភាព ៣២.៥ មិនបានសម្រេចតាមគោលដៅ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការរៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធគណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ រវាង គសហវ និង ក្រសួង ស្ថាប័ន និងនៅក្នុងក្របខណ្ឌក្រសួង ស្ថាប័ន) មិនទាន់អាចធានានិងរក្សាបានតាមគោលដៅកំណត់ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នេះ ដោយហេតុថា ការរៀបចំសកម្មភាពនិងការកំណត់សូចនាករមិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណងដែលបានកំណត់ ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី ជាពិសេស ចង្កោមសកម្មភាព ៣២.២. គឺ ការកំណត់ឱ្យបានច្បាស់ពីបន្ទាត់គណនេយ្យភាពក្នុងការរៀបចំថវិកាប្រចាំឆ្នាំនិងក្នុងការរៀបចំកម្មវិធីវិនិយោគសាធារណៈ; ចង្កោមសកម្មភាព ៣២.៤. គឺ ការកំណត់ពីការទទួលខុសត្រូវនៃការគ្រប់គ្រងនៅគ្រប់កម្រិតនិងចង្កោមសកម្មភាព, និង ៣២.៥. គឺការរៀបចំនិងចេញផ្សាយកម្រងនីតិវិធីណែនាំ ដែលពន្យល់ពីការផ្តល់សិទ្ធិអំណាចនិងការទទួលខុសត្រូវដល់អង្គភាពថវិកានិងអ្នកគ្រប់គ្រងថវិកា។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលត្រូវរៀបចំសកម្មភាពឡើងវិញឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាព ៣២.២, ៣២.៤ និង៣២.៥ នៃគោលបំណងទី២ ផ្នែកត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ដូចបានកំណត់ក្នុងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។

## ៣. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ

គោលបំណង ៣៣ នៃផ្នែកទី៣នេះ ជាគោលបំណងដែលត្រូវបានបង្កើតថ្មី ក្នុង CAP 2 New ក្នុងគោលដៅពង្រឹងការរៀបចំគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ សម្រាប់រយៈពេលវែង ដែលការងារនេះ ត្រូវបានកំណត់ក្នុង CAP 2 ដែរ តែសម្រាប់រយៈពេលខ្លីតែប៉ុណ្ណោះ។

គោលបំណងនេះ មានចង្កោមសកម្មភាពចំនួន ៣ គឺផ្តោតទៅ លើការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ តាមរយៈចង្កោមសកម្មភាព ៣៣.១. ពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច ៣៣.២. ពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម និង ៣៣.៣. ពង្រឹងសមត្ថភាពវិភាគនិងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានគោលបំណងនេះ សម្រេចបាន ៨៣% ក្នុងនោះ ចង្កោមសកម្មភាព ៣៣.១ និង ៣៣.៣ សម្រេចបាន ១០០% និង ចង្កោមសកម្មភាព ៣៣.២ សម្រេចបាន ៥០%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៣ នៃចង្កោមសកម្មភាព នៃគោលបំណង ៣៣ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាសូចនាករទាំង៣ មិនបានសម្រេចតាមគោលដៅ គឺ÷

១. ទិន្នន័យនិងស្ថិតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានបន្តរៀបចំប្រមូលផ្តុំ

២. ក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម ២០១២-២០១៤ ត្រូវបានពិនិត្យនិងកំណត់នូវភាពខ្វះខាតដើម្បីកែលម្អ ពីកម្រិតលើមកក្រោម (Top-Down Approach)

៣. តម្រូវការអញ្ញត្តម៉ូដែលម៉ាក្រូសេដ្ឋកិច្ចត្រូវបានបញ្ចប់ការសិក្សា និង ទម្រង់វិភាគនិងទិន្នន័យ ផ.ស.ស ត្រូវបានចងក្រង។

ការមិនសម្រេចតាមគោលដៅនៃសូចនាករទាំង៣ ខាងលើនេះ ដោយសារមានការលំបាកក្នុងការប្រមូលទិន្នន័យ ហើយទិន្នន័យមួយចំនួនមិនមានសុក្រឹតភាពនិងសង្គតិភាព និងបញ្ហាពេលវេលាសម្រាប់អនុវត្តសកម្មភាពដែលបានដាក់ចេញ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ មិនទាន់អាចធានានិងរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ នៅឡើយទេ ដោយហេតុថា សកម្មភាពគាំទ្រដល់ការសម្រេចបាននូវចង្កោមសកម្មភាព ៣៣.១, ៣៣.២ និង ៣៣.៣ ដែលបានកំណត់ មិនត្រូវបានអនុវត្តតាមគោលដៅគ្រោងទុក។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការបន្តពង្រឹងសមត្ថភាពរៀបចំ និងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច, បន្តពង្រឹងសមត្ថភាពរៀបចំនិងបង្កើនស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃក្របខ័ណ្ឌចំណូលចំណាយរយៈពេលមធ្យម និងបន្តពង្រឹងសមត្ថភាពវិភាគនិងព្យាករណ៍ស្ថានភាពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ៤. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ

ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុ ត្រូវបានអនុវត្តក្នុងគោលបំណង ២៧ នៃផ្នែកគណនេយ្យភាពហិរញ្ញវត្ថុ ក្នុង CAP 2 តាមរយៈការអនុវត្តចង្កោមសកម្មភាពចំនួន៨។ ដោយឡែកនៅក្នុង CAP 2 New គោលបំណងនេះ ស្ថិតនៅក្នុងផ្នែកទី៣ គឺការត្រៀមលក្ខណៈសម្រាប់ជំហានបន្ទាប់ ដើម្បីឈានទៅអនុវត្ត ដំណាក់កាលទី៣ គឺការបង្កើនការផ្សាភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយផ្តោតលើការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ ដោយហេតុថាគោលនយោបាយនិងយុទ្ធសាស្ត្រវិមជ្ឈការហិរញ្ញវត្ថុត្រូវបានរៀបចំរួចហើយក្នុងផែនការសកម្មភាពដំណាក់កាលទី២។

គោលបំណងនេះ មានចង្កោមសកម្មភាពចំនួន ៧ គឺ ៣៤.១. បន្តរៀបចំអនុក្រឹត្យ ប្រកាស សារាចរ សេចក្តីណែនាំ ដែលតម្រូវដោយច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ, ៣៤.២. រៀបចំនិងអនុវត្តគោលនយោបាយស្តីពីវិមជ្ឈការហិរញ្ញវត្ថុ រយៈពេលមធ្យមនិងវែង, ៣៤.៣. បង្កើត និងកែលម្អឧបករណ៍ អភិបាលកិច្ចទ្រទ្រង់ការរៀបចំនិងអនុវត្តថវិការបស់រដ្ឋ បាលថ្នាក់ក្រោមជាតិ, ៣៤.៤. សិក្សារៀបចំ និងអនុវត្តការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ. ៣៤.៥. បង្កើតឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោម

ជាតិ (SNIF), ៣៤.៦. រៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និង ៣៤.៧. រៀបចំផែនការកសាងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសទាក់ទិនទៅនឹងការអនុវត្ត FMIS។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបានក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ គោលបំណងនេះសម្រេចបាន ៨០%។ ដោយឡែក ចង្កោមសកម្មភាពដែលសម្រេចបានតិចជាង ៥០% គឺចង្កោមសកម្មភាព ៣៤.៦។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង ៧ នៃចង្កោមសកម្មភាព នៃគោលបំណងទី៤ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាមាន ៤ សូចនាករ នៃចង្កោមសកម្មភាព ៣៤.៣, ៣៤.៤, ៣៤.៥ និង ៣៤.៧ សម្រេចបានតាមគោលដៅ គឺ÷

១. លិខិតបទដ្ឋានគតិយុត្តស្តីពីការរៀបចំ និងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិដែលមានស្រាប់ត្រូវបានកែសម្រួលនិងកំណត់

២. សេចក្តីព្រាងគោលនយោបាយស្តីពីការប្រមូលចំណូលផ្ទាល់របស់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ

៣. សេចក្តីព្រាងឯកសារទស្សនទានស្តីពីឧបករណ៍វិនិយោគសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានរៀបចំ

៤. ផែនការកសាងសមត្ថភាពមន្ត្រីទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសទាក់ទិនទៅនឹង ការអនុវត្ត FMIS ត្រូវបានបញ្ចប់។

ដោយឡែក សូចនាករ ២ ដែលមិនសម្រេចបានតាមគោលដៅនោះ គឺ ១. លិខិតបទដ្ឋានគតិយុត្តនានាត្រូវបានរៀបចំ អនុម័ត និងផ្សព្វផ្សាយអនុវត្ត និង ២. សេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានរៀបចំ។ ការមិនសម្រេចតាមគោលដៅនេះ ដោយហេតុថាបញ្ហាពេលវេលា និងសមត្ថភាពមន្ត្រីនៅមានកម្រិតសម្រាប់រៀបចំឯកសារ។ ម្យ៉ាងទៀត សូចនាករនៃចង្កោមសកម្មភាព ៣៤.២ មិនទាន់ដល់ពេលអនុវត្តសម្រាប់ត្រីមាសទី៣ នេះទេ។

ដូចនេះ តាមការវាយតម្លៃសកម្មភាពនិងលទ្ធផលដែលសម្រេចបាន អាចសន្និដ្ឋានបានថា ការពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ នៅតែរក្សាបានតាមគោលដៅកំណត់ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ទោះបីជាការអនុវត្តសកម្មភាពនិងចង្កោមសកម្មភាពមួយចំនួនមានការយឺតយ៉ាវនិងមិនសម្រេចតាមគោលដៅក៏ដោយ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ដែលតម្រូវឱ្យខិតខំបន្ថែមទៀត ជាពិសេសបញ្ចប់ការរៀបចំសេចក្តីព្រាងគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ដើម្បីសម្រេចបានសូចនាករនេះ អគ្គនាយកដ្ឋានសាម៉ី គួរស្នើសុំជំនួយបច្ចេកទេសបន្ថែមពីអគ្គនាយកដ្ឋានថវិកា ឬ អគ្គលេខាធិការដ្ឋាន អ.គ.ហ។

## ផ្នែកទី៤: ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព

ផ្នែកទី៤ ត្រូវបានបង្កើតឡើង សម្រាប់គាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព តាមរយៈគោលបំណងចំនួន ២ រួមមាន ៤១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់ និងការទទួលខុសត្រូវ និង ៤២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើក

ទឹកចិត្ត។ គោលបំណងនីមួយៗ ត្រូវបានគាំទ្រដោយចង្កោមសកម្មភាពអនុវត្តចំនួន ២។ គោលបំណង ៤១ ជាគោលបំណងដែលត្រូវបានបង្កើតថ្មី ក្នុង CAP 2 New ក្នុងគោលដៅបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ របស់ស្ថាប័ន អង្គភាព និងមន្ត្រីរាជការ។ ដោយឡែកគោលបំណង ៤២ ដែលផ្តោតលើការបង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត មិនមានភាពខុសគ្នា ពី CAP 2 ទេ តែគោលបំណងនេះ មានភាពខុសគ្នា ក្នុងកម្រិតចង្កោមសកម្មភាព ត្រង់ថា ក្នុង CAP 2 ចង្កោមសកម្មភាពគាំទ្រ ដែលមានរហូតដល់ ១០ ត្រូវបានតម្រឹមមកត្រឹម ២ ចង្កោមសកម្មភាព ក្នុង CAP 2 New។

ជារួម ផ្អែកលើគោលបំណងដែលសម្រេចបាន ផ្នែកនេះសម្រេចបាន ៩១% ដែលក្នុងនោះគោលបំណងទី១ សម្រេចបាន ១០០% និង គោលបំណងទី២ សម្រេចបាន៨២%។ ទន្ទឹមនេះ បើពិនិត្យលើលទ្ធផលសម្រេចបាននៃសូចនាករនៃគោលបំណងទាំង២ ដើម្បីគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព ជារួម គឺសម្រេចបានតាមគោលដៅនៃសូចនាករដែលបានកំណត់ ប៉ុន្តែ ចាំបាច់ត្រូវរៀបចំសកម្មភាពនិងសូចនាករដើម្បីគាំទ្រដល់ចង្កោមសកម្មភាពនិងគោលបំណង ឱ្យមានភាពគ្រប់គ្រាន់ សុក្រឹតភាព និងសង្គតិភាព។

ដូច្នេះ ជារួម អាចសន្និដ្ឋានបានថា ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព អាចរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤នេះ តែមិនទាន់អាចឈានទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននោះទេ។ លទ្ធផលនេះបានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ ក្នុងការពង្រឹងភាពជាអ្នកដឹកនាំនិងសមត្ថភាពគ្រប់គ្រង និង បង្កើនឆន្ទៈកំណែទម្រង់ ភាពជាម្ចាស់និងការទទួលខុសត្រូវ និងការពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាពថ្មី។

## ១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ

គោលបំណង ៤១ នៃផ្នែកគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព មានចង្កោមសកម្មភាពចំនួន ២ រួមមាន ចង្កោមសកម្មភាព ៤១.១. ពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រង និង ៤១.២. បង្កើនឆន្ទៈកំណែទម្រង់ភាពជាម្ចាស់ និងការទទួលខុសត្រូវ។ ជារួម បើផ្អែកលើសកម្មភាពដែលសម្រេចបាន គោលបំណងនេះសម្រេចបាន ១០០%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង២ នៃចង្កោមសកម្មភាព នៃគោលបំណងទី១ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាសមត្ថភាពគ្រប់គ្រងត្រូវបានបង្កើន តាមរយៈការរៀបចំលក្ខខណ្ឌយោងការងារ និងបទបញ្ជាផ្ទៃក្នុង ព្រមទាំងការបណ្តុះបណ្តាលនិងការចូលរួមសិក្ខាសាលា។ ចំណែកឯ ឆន្ទៈ ភាពជាម្ចាស់ និងការទទួលខុសត្រូវ ស្តែងឡើងតាមរយៈការចូលរួមរបស់អគ្គនាយកដ្ឋាន/អង្គភាព ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការរៀបចំផែនការសកម្មភាព របស់អគ្គនាយកដ្ឋាន/អង្គភាព ឱ្យឆ្លើយតបទៅនឹងផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី។ ឆន្ទៈ ភាពជាម្ចាស់ និងការទទួលខុសត្រូវនេះ ត្រូវបានពង្រឹងបន្ថែមទៀត តាមរយៈការបង្កើតក្រុមការងារ

និងគោលការណ៍ណែនាំ/ទម្រង់ សម្រាប់ត្រួតពិនិត្យនិងវាយតម្លៃសមិទ្ធកម្ម។ សូចនាកររបស់សកម្មភាពដែលបានរៀបចំថ្មីត្បិតតែសម្រេចបានតាមគោលដៅ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ នេះក៏ដោយ ប៉ុន្តែនៅមិនទាន់បានឆ្លើយតបឱ្យបានគ្រប់គ្រាន់ ទៅតាមសូចនាករនៃចង្កោមសកម្មភាពដែលបានកំណត់។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការបង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ អាចរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ គឺមិនទាន់ឈានទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយទេ។ តាមរយៈលទ្ធផលនេះ ក៏បានឆ្លុះបញ្ចាំងអំពីភាពចាំបាច់ក្នុងការពង្រឹងនិងកែលម្អនូវការរៀបចំសកម្មភាព ឱ្យមានសុក្រឹតភាពនិងសង្គតិភាព ដើម្បីឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាព ៤១.១ និង ៤១.២ ក្នុងគោលដៅគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយប្រសិទ្ធភាព។

## ២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត

គោលបំណងទី២ នៃផ្នែកគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព មានចង្កោមសកម្មភាពចំនួន ២ រួមមាន ចង្កោមសកម្មភាព ៤២.១. ពិនិត្យមើលឡើងវិញពីប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធនៃការបណ្តុះបណ្តាល និងរៀបចំផែនការកសាងសមត្ថភាពថ្មី និង ៤២.២. ពិនិត្យមើលឡើងវិញពីយន្តការ និងអភិក្រមនៃការផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមក និងរៀបចំឱ្យមានយន្តការ និងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌និងសង្គតិភាព។ ជារួម ផ្អែកលើសកម្មភាពសម្រេចបាន គោលបំណងនេះសម្រេចបាន ៨២%។

ទន្ទឹមនេះ បើពិនិត្យមើលលទ្ធផលសម្រេចបាននៃសូចនាករទាំង២ នៃចង្កោមសកម្មភាព នៃគោលបំណងទី២ សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ ឃើញថាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការបណ្តុះបណ្តាលនិងការរៀបចំផែនការកសាងសមត្ថភាពថ្មី ត្រូវបានចូលរួមគាំទ្រតាមរយៈការរៀបចំឯកសារបណ្តុះបណ្តាល។ រីឯ យន្តការនិងអភិក្រមថ្មីស្តីពីការផ្តល់ការលើកទឹកចិត្តដែលមានសមធម៌និងសង្គតិភាព ត្រូវបានបង្កើតឡើងតាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត ពោលគឺប្រកាសលេខ ៦១៦ សហវ.ប្រក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៤ និង សារាចរលេខ ០០៨ ស្តីពីការអនុវត្តប្រកាសលេខ ៦១៦ សហវ.ប្រក ព្រមទាំងការបង្កើតគណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត នៃ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (គ.ស.ល នៃ កសហវ) និង គណៈកម្មាធិការវាយតម្លៃសមិទ្ធកម្មនិងផ្តល់ការលើកទឹកចិត្ត នៃអគ្គនាយកដ្ឋាន/អង្គភាព (គ.ស.ល នៃអង្គភាព)។ ក៏ប៉ុន្តែ សូចនាករនៃសកម្មភាពដែលគាំទ្រដល់សូចនាករនៃចង្កោមសកម្មភាព ៤២.១ តម្រូវការបណ្តុះបណ្តាលនិងការបណ្តុះបណ្តាលកន្លងមក ត្រូវបានរៀបចំនិងវាយតម្លៃ មិនទាន់បានរៀបចំឱ្យមានសុក្រឹតភាពនិងគ្រប់គ្រាន់នៅឡើយទេ ដោយសារការបណ្តុះបណ្តាលកន្លងមក មិនទាន់ត្រូវបានវាយតម្លៃ និង យន្តការនិងវិធីសាស្ត្ររួមនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋាន/អង្គភាព ក្រោមឱវាទ កសហវ នៅពេលខាងមុខ ពុំទាន់ត្រូវបានរៀបចំនៅឡើយ។

ដូចនេះ ជារួម អាចសន្និដ្ឋានបានថា ការបង្កើនប្រសិទ្ធភាព នៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត អាចរក្សាបាន សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៤ គឺមិនទាន់ឈានទៅរកស្ថិរភាពតាមគោលដៅដែលចង់បាននៅឡើយទេ។ តាមរយៈលទ្ធផលនេះ ក៏បានឆ្លុះបញ្ចាំងអំពីអាទិភាព ក្នុងការរៀបចំការវាយតម្លៃលើសមិទ្ធកម្មនៃការបណ្តុះបណ្តាលកន្លងមក

និង ការរៀបចំឱ្យមានយន្តការនិងវិធីសាស្ត្ររួមនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋាន/អង្គភាព ក្រោមឱវាទ កសហវ នៅពេលខាងមុខ ក្នុងគោលដៅគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយប្រសិទ្ធភាពនិងចីរភាព។

## IV. បញ្ហាប្រឈម

- កង្វះសមត្ថភាពក្នុងការរៀបចំម៉ូដែលព្យាករណ៍ចំណូលរបស់អង្គភាពប្រមូលចំណូល
- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ មិនអាចទទួលព័ត៌មានបានគ្រប់គ្រាន់ពីអគ្គនាយកដ្ឋានពន្ធដារ និង អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា ដើម្បីកែលម្អម៉ូដែលព្យាករណ៍ចំណូល
- កង្វះខាតទិន្នន័យមួយចំនួនសម្រាប់ធ្វើការវិភាគចីរភាពបំណុល
- នីតិវិធីនៃការងារ និងការធ្វើលទ្ធកម្មមានលក្ខណៈយូរពេក
- ភាពយឺតយ៉ាវនៃការរៀបចំនីតិវិធីអនុវត្តការងារអនាគត (To-Be Business Process) និងឯកសារវាយតម្លៃផលប៉ះពាល់សម្រាប់គម្រោង FMIS
- កង្វះសមត្ថភាពរបស់ក្រុមហ៊ុនផ្គត់ផ្គង់ប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS Contractor) ក្នុងការរៀបចំគម្រោង FMIS
- សមត្ថភាពមន្ត្រីនៅមានកម្រិតក្នុងការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំសកម្មភាពនិងការកំណត់សូចនាករ មិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណងដែលបានកំណត់
- ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការបណ្តុះបណ្តាល និង ការរៀបចំផែនការកសាងសមត្ថភាព
- កង្វះការយកចិត្តទុកដាក់ចំពោះការងារកែទម្រង់ (របាយការណ៍យឺត និងគុណភាពនៅមានកម្រិត)
- កិច្ចសហការនិងការផ្លាស់ប្តូរព័ត៌មាន ព្រមទាំងការសម្របសម្រួលរវាងអង្គភាព និង ស្ថាប័ន នៅមិនទាន់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

## V. អនុសាសន៍

- ស្នើផ្តល់របាយការណ៍វឌ្ឍនភាពប្រចាំត្រីមាសឱ្យបានទាន់ពេលវេលា
- ញែកឱ្យដាច់ពីគ្នារវាង ការងារប្រចាំថ្ងៃ និង ការងារកែទម្រង់
- គួរបង្កើនភាពជាម្ចាស់លើផែនការសកម្មភាពរបស់ខ្លួន
- អគ្គនាយកដ្ឋានដែលបង្កើតថ្មី ដែលរួមបញ្ចូលគ្នាដោយនាយកដ្ឋាន/អង្គភាពច្រើន ត្រូវរៀបចំយន្តការសម្របសម្រួលផ្ទៃក្នុងឱ្យបានសមស្រប ក្នុងការគាំទ្រដល់ការងារកែទម្រង់
- គួររៀបចំការវាយតម្លៃលើសមិទ្ធកម្មនៃការបណ្តុះបណ្តាលកន្លងមក និង ការរៀបចំឱ្យមានយន្តការនិងវិធីសាស្ត្ររួមនៃការវាយតម្លៃតម្រូវការបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋាន/អង្គភាព ក្រោមឱវាទ កសហវ

- គួររៀបចំសកម្មភាពនិងការកំណត់សូចនាករ ដែលមិនទាន់មានភាពសុក្រឹតភាពនិងសង្គតិភាពពេញលេញ ឱ្យឆ្លើយតបទៅនឹងចង្កោមសកម្មភាពនិងគោលបំណង ដែលបានកំណត់ក្នុង ផែនការសកម្មភាពរួម ដំណាក់កាលទី២ ថ្មី (CAP 2 NEW)
- ត្រូវធ្វើការត្រួតពិនិត្យឡើងវិញ លើការរៀបចំគម្រោង FMIS ដើម្បីឈានទៅរៀបចំនិងដាក់ឱ្យអនុវត្ត (Go Live) គម្រោង FMIS បាននៅខែកក្កដា ឆ្នាំ២០១៥ ដូចដែលបានកំណត់។

## VI. សេចក្តីសន្និដ្ឋាន

ជារួម របាយការណ៍ស្តីពីវឌ្ឍនភាពត្រីមាសទី៣ ឆ្នាំ២០១៤ នេះ បានបង្ហាញថា ការអនុវត្តផែនការសកម្មភាព នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៤ នៅតែអាចរក្សាបាន ទោះបីមិនទាន់អាចសម្រេចបានតាមគោលដៅសូចនាករមិទ្ធកម្មគន្លឹះគ្រប់ជ្រុងជ្រោយក៏ដោយ។ លទ្ធផលនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបានឆ្លុះបញ្ចាំងអំពីបញ្ហាប្រឈមមួយចំនួន ដែលត្រូវដោះស្រាយជាចាំបាច់ ក្នុងគោលដៅសម្រេចបាននូវ គោលដៅសូចនាករមិទ្ធកម្មគន្លឹះសម្រាប់ត្រីមាសបន្ទាប់ ក៏ដូចជាការសម្រេចបាននូវសូចនាករសមិទ្ធកម្មគន្លឹះរួម នៃផែនការសកម្មភាពទាំងមូល ផងដែរ។

ដូចនេះ អាចសន្និដ្ឋានបានថា កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតែស្ថិតលើគន្លងដ៏ត្រឹមត្រូវតាមផែនការដែលបានដាក់ចេញ។ ទន្ទឹមនេះ ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលកាន់តែមានលក្ខណៈស៊ីជម្រៅនិងស្មុគស្មាញជាងមុននោះ ទាមទារឱ្យមានការដោះស្រាយបញ្ហាប្រឈមនៅចំពោះមុខ និងការផ្លាស់ប្តូររបៀបរបបធ្វើការងារដែលគ្មានប្រសិទ្ធភាព ស្របពេលដែលការអនុវត្តថវិកាកម្មវិធី កំពុងត្រូវបានចាប់ផ្តើម នៅឆ្នាំ២០១៥ នេះ។ តាមរយៈបទពិសោធន៍ដែលទទួលបានពីការអនុវត្តកម្មវិធីកែទម្រង់កន្លងមក បានបង្ហាញថា សមត្ថភាពដឹកនាំនិងគ្រប់គ្រង ស័ក្តិសិទ្ធភាពនៃការប្រើប្រាស់មន្ត្រីនៅមានកម្រិត។ ប្រការនេះ ទាមទារឱ្យមានការបែងចែកមុខងារភារកិច្ចឱ្យសមស្របនិងច្បាស់លាស់ជាងមុន ព្រមទាំងការអនុវត្តគោលការណ៍ ក៏ដូចជាវិន័យឱ្យបានម៉ឺងម៉ាត់ ដែលជាមូលដ្ឋានធានាឱ្យមាន សមិទ្ធកម្មល្អ ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពខ្ពស់។ ម្យ៉ាងទៀត ភាពជាម្ចាស់ ការទទួលខុសត្រូវ និងគណនេយ្យភាព ត្រូវបានចាត់ទុកជាគោលការណ៍គន្លឹះសម្រាប់ដំណាក់កាលនេះផងដែរ។

ជាទីបញ្ចប់ ក្នុងការបំពេញមុខងារ ដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ព្រមទាំងក្នុងការសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្តេជ្ញាបន្តអនុវត្តដើម្បីសម្រេច ផែនការសកម្មភាព ដែលជាឧបករណ៍គន្លឹះសម្រាប់គាំទ្រដល់ជោគជ័យនៃដំណាក់កាលទី២ ដើម្បីអាចឈានទៅចាប់ផ្តើមការអនុវត្តដំណាក់កាលទី៣ គឺ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ដោយប្រកាន់យក "លទ្ធផល ឬ សមិទ្ធកម្ម" ជាអភិក្រមនៃការអនុវត្តសកម្មភាព ក្នុងគោលដៅ អភិបាលកិច្ចល្អ ដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។